**មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំ ខប់សែលឡឹម លើកទី ១

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃអង្គារ ទី២៩ ខែកញ្ញា ឆ្នាំ២០០៥**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

១. មតិស្វាគមន៍ ថ្លែងដោយលោក ឡារី ស្ត្រេន្ទ នាយកប្រតិបត្តិ វ.ប.ស.អ.

២. បទឧទ្ទេសនាមរបស់អ្នកសម្របសម្រួលយន្តការ ខប់សែល

៣. អំពីបែបបទនៃការប្រជុំ "ខប់សែលឡឺម-COPCELEM"

៤. ស្ថានភាពទូទៅទាក់ទិននឹងការរៀបចំដំណើការបោះឆ្នោត ក្នុងពេលបីឆ្នាំខាងមុខ ថ្លែងដោយ ឯកឧត្តមអគ្គលេខាធិការរង គជប

៥. មតិរបស់សមាជិកអង្គប្រជុំឆ្លើយតបទៅនឹងបទឧទ្ទេសនាមរបស់ឯកឧត្តមអគ្គលេខាធិការរង និងការពិភាក្សាអំពីរបៀបវារៈជាយុទ្ធសាស្ត្ររបស់ "ខប់សែល-COPCEL" ក្នុងពេលបីឆ្នាំខាងមុខ

៦. សេចក្តីផ្សេងៗ

ក្នុងនាមជាទីប្រឹក្សានៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) និងជាអ្នកសម្របសម្រួលកិច្ចប្រជុំខប់សែល លោក **ឱក សេរី សោភ័ក្តិ** បានស្វាគមន៍ដល់សមាជិកអង្គប្រជុំដែលបានចំណាយពេលដ៏មានតម្លៃយ៉ាង និងអញ្ជើញមកចូលរួមក្នុងអង្គប្រជុំ ខប់សែលឡឺម-COPCELEM លើកទីមួយ នៃយន្តការខប់សែលដំណាក់កាលទី២នេះ ។ លោកបានបន្តថា ដោយសារនេះជាកិច្ចប្រជុំលើកទីមួយរបស់ ខប់សែលឡឺម-COPCELEM របៀបវារៈនេះ ជារបៀបវារៈដំបូង ដូចនេះ នឹងមិនមានការកែប្រែទេ តែចាប់ពី ខប់សែលឡឺម-COPCELEM លើកទីពីរទៅ របៀបវារៈនឹងបានមកពីសមាជិកទាំងអស់របស់ ខប់សែលឡឺម-COPCELEM ។ លោកបានបញ្ជាក់ថា យន្តការខប់សែល-COPCEL លើកទី២នេះ គឺសំរាប់ដំណើរការរយៈពេល៣ឆ្នាំខាងមុខ ដែលបានទទួលការគាំទ្រយ៉ាងពេញទំហឹងពីអង្គការ UNDP បន្ទាប់ពីយន្តការខប់សែលលើកទី១ចាប់ពីឆ្នាំ១៩៩៩ រហូតដល់ ឆ្នាំ២០០៣ ដែលត្រូវបានទទួលស្គាល់ជាទូទៅថាជាយន្តការមួយជួយកាត់បន្ថយទំនាស់ក្នុងដំណើរការបោះឆ្នោតនៅកម្ពុជា ។ ខប់សែល ដំណាក់កាលទី២នេះមាន៦រចនាសម្ព័ន្ធដែលត្រូវរៀបចំកិច្ចប្រជុំពីថ្នាក់ជាតិរហូតដល់ថ្នាក់ខេត្ត-ក្រុង គឺខុសប្លែកពី ខប់សែលលើកទី១ ដែលផ្តោតតែនៅថ្នាក់ជាតិ។ បន្ទាប់មកលោកបានប្រកាសរបៀបវារៈដល់អង្គប្រជុំ។

## ១. មតិស្វាគមន៍ ដោយលោក ឡារី ស្ត្រេន្ទ នាយកប្រតិបត្តិវិទ្យាស្ថាន វបសអ

លោកបានថ្លែងថា នេះគឺជាកិត្តិយសដ៏ធំធេងរបស់លោកដែលបានធ្វើការទទួលស្វាគមន៍ សមាជិកទាំងអស់នៃកិច្ចប្រជុំខប់សែលឡឺមលើកទី១នេះ ។ ឆ្លៀតក្នុងឱកាសនោះផងដែរ លោកបានថ្លែងអំណរគុណជាពិសេសជូនដល់លោកស្រី **ប៉ុក បញ្ញាវិចិត្រ** ដែលនៅពេលថ្មីៗនេះ លោកស្រីបានធ្វើការនៅក្នុងអង្គការ UNDP បានជួយគាំទ្រយ៉ាងធំធេងដល់ដំណើរការខប់សែលនេះ។ លោកបានចាំថាមានសមាជិកអង្គប្រជុំជាច្រើនដែលមានវត្តមាននៅទីនេះ បានយ៉ាង និងអញ្ជើញចូលរួមនៅក្នុងអង្គសន្និសីទថ្នាក់ជាតិដើម្បីចាប់ផ្តើមដំណើរការយន្តការខប់សែលដំណាក់កាលទី២ ដែលរៀបចំធ្វើនៅសណ្ឋាគារភ្នំពេញកាលពីខែកក្កដា ២០០៥ កន្លងមកនេះ ។ ចំពោះ

សមាជិកដែលមិនបានអញ្ជើញចូលរួមក្នុងអង្គសន្និសីទនោះ លោកសូមរំលឹកឡើងជាថ្មីនូវចំណុច ៣ ស្តីអំពីសារៈសំខាន់នៃយន្តការខប់សែល និងការជួយឧបត្ថម្ភរបស់ CDRI នៅក្នុងដំណើរការនេះ ។

**ចំណុចទី១** ខប់សែល គឺជាយន្តការមួយរបស់កម្ពុជាសុទ្ធសាធ ដែលចាប់ដំណើរការឡើងវិញ ដើម្បីសំរេចនូវសមិទ្ធផលផ្សេងៗទៀតជាច្រើន។ យន្តការខប់សែលនេះ បានបង្កើតឡើងដោយប្រជាជនកម្ពុជាសុទ្ធសាធ និងដំណើរការដោយជនជាតិកម្ពុជាសុទ្ធសាធ ហើយនិងចូលរួមដោយជនជាតិកម្ពុជា ហើយនោះគឺជាមោទនៈភាពមួយយ៉ាងធំធេង និងជាសមិទ្ធិផលមួយល្អណាស់ដែលអ្នកពាក់ព័ន្ធរបស់ខប់សែល មានមោទនភាព និងឱ្យតម្លៃយ៉ាងខ្លាំងចំពោះយន្តការនេះ ។ **ចំណុចទី២** យន្តការខប់សែលនេះត្រូវបានរៀបចំបង្កើតឡើងសំរាប់ដោះស្រាយបញ្ហា និងការងារមួយចំនួន ។ គោលបំណងយ៉ាងធំរបស់ ខប់សែល គឺថាការពារដើម្បីកុំឱ្យមានទំនាស់ ការពារមិនឱ្យមានអំពើហិង្សា និងជៀសវាងនូវការភាន់ច្រឡំនៅក្នុងដំណើរការបោះឆ្នោត និងកសាងនូវវប្បធម៌នៃការពិភាក្សាគ្នា ហើយចំពោះដំណើរការ និងសកម្មភាពនានា គឺដើម្បីកសាងនូវទំនុកចិត្ត និងការសាមគ្គីគ្នាដើម្បីដំណើរការនៅអនាគត ។ ហើយ **ចំណុចទី៣** ក៏ជាចំណុចមួយមានសារៈសំខាន់ផងដែរ ដែល CDRI ក្នុងដំណើរការនេះបានបង្កើតឡើងដោយ គំហើញ និងដោយគំនិតផ្សេងៗ ដែលបង្កើតឡើងដោយអ្នកស្រាវជ្រាវដែលមានលក្ខណៈវិជ្ជាជីវៈអាជីព និងមានឯករាជ្យភាព ។ នៅក្នុងឆ្នាំ១៩៩៨ CDRI បានធ្វើការស្រាវជ្រាវអំពីដំណើរការនៃការបោះឆ្នោត ព្រមទាំងស្ថាប័ននៃការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជា ហើយចាប់តាំងពីដំណើរការនៃការបោះឆ្នោតលើកទីមួយមក តាមការស្រាវជ្រាវនោះមានការសង្កេតឃើញថា មានការកែលំអច្រើន ទាំងស្ថាប័ននៃការបោះឆ្នោត ក៏ដូចជាដំណើរការនៃការបោះឆ្នោតផ្សេងៗ។ ក៏ប៉ុន្តែទោះជាមានសមិទ្ធផលជាវិជ្ជមានទាំងនេះក៏ដោយ ក៏នៅមានបញ្ហាមួយចំនួនទៀតដែរ ដែលត្រូវធ្វើការកែលំអ រួមទាំងដំណើរការនៃការបោះឆ្នោត ស្ថាប័ននៃការបោះឆ្នោតនោះ គឺជាដំណាក់កាលទី១របស់ខប់សែល ហើយដំណាក់កាលទី២ របស់ខប់សែល បានបង្កើតឡើងអំពីគំនិត និងការរកឃើញនូវការស្រាវជ្រាវទាំងនោះ ។ លោកបានបញ្ជាក់ថា ខប់សែលដំណាក់កាលទី២នេះ គឺយើងធ្វើការពិភាក្សាជាមួយនឹងថ្នាក់ជាតិ ដោយមានការចូលរួមពីថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុងផង ព្រមទាំងមានការពិគ្រោះយោបល់ជាមួយនឹងថ្នាក់សហគមន៍ផងដែរ។ វិទ្យាស្ថាន CDRI រំពឹង និងយល់ឃើញថា មតិ គំនិត និងយោបល់របស់សមាជិកទាំងអស់នឹងមានសារៈសំខាន់ជាទីបំផុតក្នុងដំណើរការអភិបាលកិច្ចប្រកបដោយប្រជាធិបតេយ្យ និងដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ។ យើងជឿជាក់ថា ដំណើរការរៀបចំ និងកសាងស្ថាប័នប្រកបដោយប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ក្រោយពេលមានសង្គ្រាម និងជំលោះមកនោះ គឺជាដំណើរការមួយដែលមានសភាពយឺតយ៉ាវ និងចំណាយពេលវែងក្នុងដំណើរការនៅក្នុងប្រទេសកម្ពុជា ។ ហើយតាមរយៈការអញ្ជើញចូលរួមរបស់សមាជិកទាំងអស់នៅទីនេះ គឺបានបង្ហាញនូវការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីលើកទឹកចិត្តយើងឱ្យបានកាន់តែច្រើនថែមទៀត ដែលយើងយល់ឃើញថា យន្តការនេះនឹងដំណើរការទៅប្រកបដោយជោគជ័យ និងទទួលលទ្ធផលជាវិជ្ជមាន ។ ជាបន្ទាប់លោកបានប្រគល់វេទិកានេះទៅលោក **ឱក សេរី សោភ័ក្តិ** ដើម្បីជំរាបជូនអង្គប្រជុំអំពីដំណើរការរបស់ខប់សែលនៅដំណាក់កាលទី២នេះ ។

## ២. បទឧទ្ទេសនាមរបស់អ្នកសម្របសម្រួលស្តីពីយន្តការខប់សែល

លោក ឱក សេរី សោភក្តិ៍ បានថ្លែងអំណរគុណចំពោះលោក ឡារី ស្ត្រេន្ទ ដែលបានមានមតិយ៉ាងក្បោះក្បាយអំពីយន្តការខប់សែល និងបានប្រគល់វេទិកាមកឱ្យរូបលោកបន្ត។ ដោយសារកិច្ចប្រជុំនេះជាលើកទី១ លោកសូមស្នើឱ្យសមាជិកទាំងអស់មេត្តាណែនាំខ្លួន (ឈ្មោះ និងស្ថាប័ន) ជូនអង្គប្រជុំដើម្បីងាយស្រួលក្នុងការទំនាក់ទំនងគ្នា និងក្នុងការធ្វើកំណត់ហេតុផងដែរ។

លោកបានបញ្ជាក់ជូនអង្គប្រជុំថា យន្តការខប់សែលនេះមានការចូលរួម និងបញ្ចេញមតិស្មើភាពគ្នាដើម្បីក្លាយជាបរិយាកាសគ្រួសារតែមួយ បរិយាកាសដែលជិតដិត អត់មានឋានានុក្រម អត់មានអ្នកធំអ្នកតូចទេ គឺថាអ្នកណាមកមុនអង្គុយមុន គឺអត់មានកន្លែងសំរាប់អ្នកធំ អត់មានកន្លែងសំរាប់អ្នកតូចទេ ព្រោះយើងចង់ឱ្យជិតគ្នា កុំឱ្យនៅក្នុងសង្គមខ្មែរមានការឃ្លាតឆ្ងាយពីគ្នា។ ដូចនេះនៅទីកន្លែងនេះ យើងចង់កសាងបរិយាកាស ដែលមន្ត្រីធំយ៉ាងណាក៏ដោយ អ្នកតូចយ៉ាងណាក៏ដោយ ក៏មានអារម្មណ៍ថាយើងនៅជិតគ្នា ដើម្បីឱ្យយើងអាចនិយាយជាមួយគ្នាបានយ៉ាងអស់ចិត្ត និងអត់មានការរារែកនៅក្នុងអារម្មណ៍របស់យើង។

នៅក្នុងខប់សែលដំណាក់កាលទី២នេះ មានរហូតដល់៦រចនាសម្ព័ន្ធគឺមិនធ្វើតែមួយដូចកាលពីឆ្នាំ១៩៩៩ ទៅដល់ ២០០៣ទេ ។ យើងបានប្រជុំ ខប់សែលខម ចំនួន២ដងរួចមកហើយ ហើយខប់សែលខម គឺមានន័យថា COPCEL CORE MEETING គឺជាខប់សែលប្រជុំស្នូលដែលធ្វើមួយខែម្តង និងមានសមាជិកប្រហែល១៥-១៦នាក់ប៉ុណ្ណោះ ហើយអ្នកទាំងនោះសុទ្ធតែជាអ្នកឯកទេសផ្នែកបោះឆ្នោត និងច្បាប់ដែលបានចូលរួមនៅក្នុងការបោះឆ្នោត។ រីឯខប់សែលឡឹម យើងប្រជុំ៣ខែម្តងដើម្បីកុំឱ្យរំខានពេលវេលាច្រើនរបស់សមាជិកអង្គប្រជុំដែលមានភារកិច្ចដ៏មមាញឹករួចទៅហើយ។ ក៏ប៉ុន្តែបើសិនជាមានសំណូមពរចាំបាច់ពីសមាជិកអង្គប្រជុំ កិច្ចប្រជុំនេះអាចនឹងកែប្រែបាន ជាពិសេសពេលជិតដល់ថ្ងៃបោះឆ្នោត។

ហើយបន្ទាប់ពីនេះ យើងមាន ខប់សែលប្រ៊ម COPCEL PROVINCIAL MEETINGS តែមុននឹងដំណើរការកិច្ចប្រជុំនេះ យើងនឹងចុះទៅខេត្ត-ក្រុងដើម្បីធ្វើការវាយតម្លៃជាមុនដោយយើងចែកប្រទេសកម្ពុជាជា៧តំបន់ ដែលជំហានដំបូងយើងចុះទៅតំបន់ ទី១ គឺតាកែវ កំពត ក្រុងព្រះសីហនុ និងកំពង់ស្ពឺ ដែលគ្រោងពីថ្ងៃទី១០-១៥ តុលា ២០០៥។ ហើយនៅក្នុង៣ឆ្នាំខាងមុខ យើងនឹងធ្វើការប្រជុំ៤៨ដង នៅក្នុងខេត្ត-ក្រុងទាំង ២៤ គឺ២ដងក្នុងមួយខេត្ត-ក្រុង ដើម្បីឱ្យវប្បធម៌នៃការជជែកគ្នា និងវប្បធម៌នៃការបង្ការទំនាស់បានជ្រួតជ្រាបទៅដល់ថ្នាក់មូលដ្ឋាន។ យើងនឹងធ្វើការប្រទាក់ក្រឡាជាមួយនឹងអង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានដើម្បីឱ្យដំណើរការបោះឆ្នោតមានភាពល្អប្រសើរ។ ដូច្នេះហើយយើងចង់ឱ្យមានការជជែកពិភាក្សាគ្នាទៅដល់ថ្នាក់មូលដ្ឋាន ។

## ៣. របៀបរបបនៃកិច្ចប្រជុំខប់សែលឡឹម

លោក ឱក សេរី សោភក្តិ៍ បានជំរាបសមាជិកអង្គប្រជុំថា ពេលសមាជិកណាម្នាក់មានមតិ សូមមេត្តាប្រើក្បាលមីក្រូហ្វូនដើម្បីងាយស្រួលសំរាប់ខាងលេខាធិការដ្ឋានថតសម្លេង ហើយអ្វីដែលនិយាយទាំងប៉ុន្មានកត់ចូលទៅក្នុងកំណត់ហេតុ ហើយខាងលេខាធិការដ្ឋានមិនអាចមានសិទ្ធិកែប្រែអត្ថន័យទេ គ្រាន់តែជួយកែសំរួលឃ្លោងឃ្លាឱ្យទៅតាមរបៀបសរសេរតែប៉ុណ្ណោះ។ លោក

បានបញ្ជាក់ថា កំណត់ហេតុនេះមានសារៈសំខាន់ណាស់សំរាប់យន្តការ ខប់សែល ព្រោះធ្វើឱ្យអ្នកដែលមានមតិយោបល់ មានការទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបាននិយាយ ហើយកំណត់ហេតុនេះត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ព្រះមហាវីរៈក្សត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា នាយករដ្ឋមន្ត្រី រហូតដល់រដ្ឋមន្ត្រីពាក់ព័ន្ធមួយចំនួន អភិបាល អភិបាលរងខេត្ត-ក្រុង។ ឆ្លៀតក្នុងឱកាសនេះផងដែរ លោកបានថ្លែងអំណរគុណដល់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានរបស់ក្រសួងមហាផ្ទៃ និងកម្មវិធីសីលា PLG ដែលបានចូលរួមសហប្រតិបត្តិការដើម្បីយកកំណត់ហេតុនេះទៅចែកចាយរហូតទៅដល់ថ្នាក់ស្រុក-ខ័ណ្ឌ និងឃុំ-សង្កាត់។ លោកបានឆ្លៀតឱកាសនេះ ដើម្បីចូលរួមជាមួយលោក **ឡាវី ស្រេន្ទ** សំដែងនូវអំណរគុណដល់អ្នកស្រី **ប៉ុក បញ្ញាវិចិត្រ** ដែលបានជួយជ្រោមជ្រែងឱ្យ UNDP ផ្តល់មូលនិធិសំរាប់យន្តការខប់សែលដំណាក់កាលទី២នេះរហូតដល់ថ្នាក់ខេត្ត-ក្រុង។

លោកបានសំណូមពរដល់សមាជិករបស់ ខប់សែលឡឹម ថានៅពេលមានប្រសាសន៍ គឺធ្វើយ៉ាងណាមេត្តាជៀសវាងការបរិហារកេរ្តិ៍ ការវាយប្រហារ និងការចោទប្រកាន់គ្នា ព្រោះតែកាលណាចូលទៅក្នុងកំណត់ហេតុហើយ មិនអាចដូរបានតាមចិត្តទេ ហើយកំណត់ហេតុនេះត្រូវផ្ញើទៅកន្លែងសំខាន់ៗ ហើយមានអ្នកអានច្រើនណាស់។ ក៏ប៉ុន្តែមតិលើកឡើងជុំវិញយន្តការបោះឆ្នោត គឺបានដោយសេរី អត់មានអ្នកណាមកបង្ខិតបង្ខំទេ គឺយើងរក្សាការគួរសម រក្សាការគោរពស្រឡាញ់គ្នាទៅវិញទៅមក ហើយយើងជឿថាទំនាស់បើសិនជាយើងជជែកគ្នានៅក្នុងលក្ខណៈនេះ យើងពិតជាអាចបង្ការ និងដោះស្រាយបាន។

លោកបានជំរាបសមាជិកអង្គប្រជុំថា ខប់សែលដំណាក់កាលទី១ យើងគ្រាន់តែធ្វើការបង្ការ ក៏ប៉ុន្តែខប់សែលដំណាក់កាលទី២នេះ យើងចង់រុញមួយជំហានទៅមុខទៀត រហូតទៅដល់យន្តការដោះស្រាយ។ លោកបានលើកយកឧទាហរណ៍២ ដែលជួបប្រទះនៅក្នុងខប់សែលទី១ និងនៅក្នុងឆ្នាំនេះ នូវបញ្ហាពីរធំៗក្នុងចំណោមបញ្ហា ៦-៧ គឺបញ្ហាអត្តសញ្ញាណប័ណ្ណ និងការចុះឈ្មោះបោះឆ្នោត ។ បញ្ហាអត្តសញ្ញាណប័ណ្ណ យើងត្រូវរកវិធីដោះស្រាយធ្វើយ៉ាងណាកុំឱ្យក្លាយជាបញ្ហានៅក្នុងប្រទេសកម្ពុជាទៀត។ ហើយលោកបានឆ្លៀតឱកាសនេះផងដែរ ដើម្បីថ្លែងនូវអំណរគុណដល់ក្រសួងមហាផ្ទៃ និងឧត្តមសេនីយទោ **ណុប ស៊ីណូ** និងសហការីទទួលបន្ទុកកិច្ចការស្ថិតិដែលបាននាំយកឯកសារទាក់ទងនឹងអត្តសញ្ញាណប័ណ្ណនេះមកជំរាបជូនសមាជិកអង្គប្រជុំ ព្រោះអត្តសញ្ញាណប័ណ្ណគឺជាឯកសារសំខាន់សំរាប់ពលរដ្ឋខ្មែរទាំងអស់ ហើយក៏ជាឯកសារសំខាន់សំរាប់ប្រើការនៅក្នុងការចុះឈ្មោះបោះឆ្នោត។ ដូចនេះ យើងគិតពីនេះទៅ៣ឆ្នាំខាងមុខ បញ្ហាអត្តសញ្ញាណប័ណ្ណនឹងលែងចោទទៀតហើយ ជាពិសេសចំពោះអ្នកដែលដល់អាយុបោះឆ្នោត និងកម្មកររោងចក្រជាដើម។ រឿងចុះឈ្មោះបោះឆ្នោតយើងបានឃើញថា ខាង គជប បានខំប្រឹងប្រែងខ្លាំងណាស់តាំងពី pre-registration ៩ខែរហូតដល់ចុះឈ្មោះ។ ក្នុងអាទិត្យក្រោយនេះ យើងនឹងចាប់ផ្តើមចុះឈ្មោះជាផ្លូវការ ហើយរហូតទៅដល់ថ្ងៃ៣១ធ្នូ បីខែនេះគឺថាជាជំហានធំណាស់ យើងចង់ឱ្យបីឆ្នាំទៅមុខរឿងបញ្ហាចុះឈ្មោះដែលស្មៀនឃុំ-សង្កាត់ បានទទួលភារកិច្ចទៅតាមច្បាប់នោះលែងទៅជាបញ្ហានៅក្នុងព្រះរាជាណាចក្រកម្ពុជាទៀត។

លោកបន្តថា ខប់សែល បានដើរតួនាទីសំខាន់ណាស់នៅក្នុងការបង្ការ និងដោះស្រាយទំនាស់ ដូច្នេះវិទ្យាស្ថាន CDRI រួមជាមួយសមាជិកទាំងអស់ និងដៃគូពាក់ព័ន្ធគឺជាកម្លាំងចលករ និងជាតួអង្គសំរាប់ធ្វើឱ្យរឿងទាំងអស់នេះកើតឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងស្មារតីមួយដែលមានការសហប្រតិបត្តិជាផ្លូវការ។ ជាបន្តលោកបានប្រគល់វេទិកាជូនឯកឧត្តមអគ្គលេខាធិការរង គជប ដើម្បីជំរាបអង្គប្រជុំនូវខ្លឹមសាររបៀបវារៈទី៤។

## ៤. ស្ថានភាពនូវទៅទាក់ទងនឹងការរៀបចំដំណើរការបោះឆ្នោតក្នុងពេល៣ឆ្នាំខាងមុខ

ឯកឧត្តម **សុកុលៈ ទីប៉ោ** អគ្គលេខាធិការរង គជប បានថ្លែងថា នេះជាលើកទីមួយហើយដែលឯកឧត្តមមានកិត្តិយសបានចូលរួមក្នុងខប់សែលឡឹម ហើយ ខប់សែលមុនៗ ឯកឧត្តមប្រធាន គជប និង ឯកឧត្តមអគ្គលេខាធិការបានមានមតិយ៉ាងច្រើនហើយអំពីការងាររបស់ គជប ក្នុងការបោះឆ្នោត។ ឯកឧត្តមបានបន្តថា យន្តការ ខប់សែល គឺជាកិច្ចប្រជុំមួយដ៏ល្អសំដៅជួយបង្កលក្ខណៈឱ្យសង្គមកម្ពុជាមានសមធមិ និងមានសេចក្តីក្លាហានប្រកបដោយភាពថ្លៃថ្នូរក្នុងការប្រយុទ្ធដណ្តើមលើឆាកប្រជាធិបតេយ្យនៃការបោះឆ្នោតដោយប្រើគតិបណ្ឌិត និងឈរលើមនសិការបំរើឱ្យផលប្រយោជន៍ពិតៗ។ ក្នុងរយៈពេល៣ឆ្នាំ ខាងមុខ គជប មានភារកិច្ចរៀបចំការបោះឆ្នោតជាបន្តបន្ទាប់ រួមមានការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងការជ្រើសតាំងតំណាងរាស្ត្រ ។ ចំពោះដំណើរការនៃការរៀបចំភារកិច្ចរបស់ខ្លួន គជប បានឈរលើស្ថានភាពដូចខាងក្រោមៈ

- **ទី១** គជប បានទទួលនូវឥទ្ធិពលនៃសង្គម យើងសង្កេតឃើញថា បរិយាកាសនៃដំណើរការបោះឆ្នោតកន្លងមក លទ្ធផលនៃការបោះឆ្នោតទទួលបានជោគជ័យតាមផ្លូវច្បាប់។ ប៉ុន្តែចំពោះទិដ្ឋភាពសង្គមវិញ យើងឃើញថា មិនទាន់ទទួលជោគជ័យបានទាំងស្រុងទេ ព្រោះចាប់តាំងពីការរៀបចំការបោះឆ្នោតដោយអ៊ុនតាក់ និងដោយខ្មែរខ្លួនឯងមក គណបក្សដែលចាញ់ឆ្នោតតែងពុំព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ហើយចុងបញ្ចប់គាត់បានរកនីតិវិធីចរចាសំរបសំរួលដើម្បីរកច្រកចេញក្នុងយុទ្ធសាស្ត្របែងចែកអំណាចដឹកនាំជាតិតាមរបត់រាជរដ្ឋាភិបាលចំរុះច្រើនគណបក្ស ឬទ្វេគណបក្សដោយពុំដែលមានលទ្ធផលនៃការបោះឆ្នោតណាមួយដែលគណបក្សណាមួយទទួលបានដាច់គេណាស់ក្នុងរដ្ឋសភាដើម្បីផ្ទេរផ្គងគ្នាឱ្យកាន់តំណែងផ្សេងៗ ក្នុងរដ្ឋាភិបាលដោយសន្តិវិធីនោះទេ។ ម្យ៉ាងទៀត គជប បានរងនូវការរិះគន់ឥតសំចៃដែលមានមជ្ឈដ្ឋានខ្លះថា ជាអង្គការរៀបចំការបោះឆ្នោតតាមបញ្ជា លទ្ធផលការបោះឆ្នោតបានកំណត់រួចជាស្រេច បានចំណាយថវិកាជាច្រើន គ្មានអព្យាក្រឹតក្នុងការងារសំដៅធ្វើយ៉ាងណាឱ្យមតិជាតិ និងអន្តរជាតិ ជាពិសេសប្រជារាស្ត្រក្រីក្រអស់ជំនឿលើយន្តការបោះឆ្នោត និងលែងចាប់អារម្មណ៍យកចិត្តទុកដាក់ដល់ការងារពាក់ព័ន្ធដំណើរការបោះឆ្នោត ឬចុះឈ្មោះប្រចាំឆ្នាំដោយមិនយល់អំពីផលប្រយោជន៍នៃដំណើរការបោះឆ្នោត។
- **ទី២** កាតព្វកិច្ច និងគោលជំហររដ្ឋធម្មនុញ្ញបានកំណត់ឱ្យ គជប ទទួលសិទ្ធិ និងអំណាចរៀបចំដំណើរការបោះឆ្នោតដោយអនុវត្តន៍តាមច្បាប់ស្តីពីការបោះឆ្នោតនីមួយៗ តែគ្មានសមត្ថកិច្ចកែប្រែមាត្រាណាមួយទេ ។ គជប ជាស្ថាប័នរដ្ឋធម្មនុញ្ញក្រោមបាវចនា ឯករាជ្យ អព្យាក្រឹត សច្ចៈ យុត្តិធមិ និងតម្លាភាព ឥស្សរជនខ្មែរដឹកនាំ គជប ជាបញ្ញាវ័ន្តខ្មែរសុទ្ធសាធមានកេរ្តិ៍ឈ្មោះល្អ មានសមត្ថភាពខ្ពស់ មានជំហរមិនលំអៀង ស្រឡាញ់កិត្តិយស ស្រឡាញ់សេចក្តីថ្លៃថ្នូរ ហើយប្រឈមមុខចំពោះប្រវត្តិសាស្ត្ររបស់ជាតិ មិនតែប៉ុណ្ណោះ គាត់បានសច្ចាប្រណិធានចំពោះព្រះមហាស្វេតឆ័ត្រចំពោះព្រះភក្ត្រព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូងនៅក្នុងព្រះរាជវាំង។ ឈរលើទស្សនៈនេះ ឯកឧត្តសូមឱ្យមជ្ឈដ្ឋាននានាមានសុទិដ្ឋិនិយមលើគោលជំហរនៃការដឹកនាំរបស់ គជប ហើយត្រូវមានជំនឿថា ឥស្សរជនទាំងអស់មិនហ៊ានក្បត់សតិសម្បជញ្ញៈ និងក្បត់សម្បថរបស់គាត់ទេ ។

- **ទី៣** យន្តការការងារ គជប បានកែសំរួលនីតិវិធី ឱ្យស្របទៅតាមសភាពការណ៍ជាក់ស្តែងក្នុងដំណើរការរៀបចំការបោះឆ្នោតនីមួយៗ ដើម្បីជំរុញការងារឱ្យមានប្រសិទ្ធភាព និងទទួលជោគជ័យ ដូចជាធ្វើសេចក្តីណែនាំរួមរវាង គជប និងក្រសួងមហាផ្ទៃ ស្តីពីការរៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះប្រចាំឆ្នាំ។ នេះគឺជាយន្តការមួយដែលអាចទទួលបាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជារាស្ត្រ ដែលមិនបានចុះឈ្មោះ និងទើបគ្រប់អាយុចុះឈ្មោះ មានពេលវេលាគ្រប់គ្រាន់ក្នុងការចុះឈ្មោះ ឬបំពេញឯកសារដើម្បីចុះឈ្មោះ ឬពិនិត្យតាមដានឈ្មោះ ក្នុងករណីមានការផ្លាស់ប្តូរការិយាល័យឬខុសអក្ខរាវិរុទ្ធ។ ជាពិសេសគណបក្សនយោបាយមានពេលវេលាគ្រប់គ្រាន់ក្នុងការជំរុញជ្រោមជ្រែងឱ្យសមាជិករបស់ខ្លួនបានទៅចុះឈ្មោះគ្រប់ៗគ្នា និងអាចមានពេលវេលាគ្រប់គ្រាន់ សំរាប់តាមដានចំពោះការយល់ឃើញរបស់គណបក្សខ្លួនថា គជប មានភាពមិនប្រក្រតីក្នុងការធ្វើបញ្ជីឈ្មោះប្រចាំឆ្នាំ និងបញ្ជីឈ្មោះបោះឆ្នោត ។ គជប បានរៀបចំរចនាសម្ព័ន្ធ តាមឋានានុក្រម ពីថ្នាក់ជាតិ ដល់មូលដ្ឋាន ព្រមទាំងរៀបចំផែនការមេ ប្រក្រតិទិន និងចងក្រងបទបញ្ជា នីតិវិធីសំរាប់ដំណើរការបោះឆ្នោតនីមួយៗ យោងតាមច្បាប់ដែលប្រកាសឱ្យប្រើប្រាស់។ គ្រប់ការតាក់តែងនីតិវិធី និងបទបញ្ជាសំរាប់ដំណើរការបោះឆ្នោតនីមួយៗ គជប បានធ្វើសន្និសីទសារព័ត៌មាន និងផ្សាយជូនដល់ស្ថាប័ននីតិបញ្ញត្តិ គណបក្សនយោបាយ និង សង្គមស៊ីវិល ឱ្យចូលរួមផ្តល់អនុសាសន៍កែសំរួលក្នុងការតាក់តែងនេះដើម្បីឱ្យការគ្រប់គ្រង និងដំណើរការបានប្រព្រឹត្តទៅប្រកបដោយភាពរលូន មានប្រសិទ្ធភាព និងជោគជ័យក្នុងការតាក់តែងបទបញ្ជា នីតិវិធីសំរាប់រៀបចំការបោះឆ្នោតព្រឹទ្ធសភា។ មានតែរដ្ឋសភា និងគណបក្សប្រជាជនកម្ពុជាទេ ដែលបានផ្តល់អនុសាសន៍ ស្នើសុំកែសំរួលចំណុចមួយចំនួន នេះបញ្ជាក់ឱ្យឃើញថា មជ្ឈដ្ឋានមួយចំនួនមានតែការរិះគន់ ហើយគ្មានឆន្ទៈចូលរួមកែសំរួលនូវរាល់ចំណុចទាំងឡាយណាដែលខ្លួនយល់ថា មិនសមស្របទៅតាមលក្ខណៈបច្ចេកទេសនៃគតិច្បាប់របស់ គជប ។
- **ទី៤:** យោងលើរបាយការណ៍ក្រសួងមហាផ្ទៃ យើងឃើញថា ការចេញអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ទើបតែបាន ៧០% នៅខ្វះ ៣០% (ប្រហែលជាង២លាននាក់) ប្រសិនបើក្នុងករណីក្រសួងមហាផ្ទៃមិនអាចចេញអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋបានទេ នៅក្នុងការបោះឆ្នោតខាងមុខនឹងមានបញ្ហាខ្លះ ។ ច្បាប់បោះឆ្នោតបានកំណត់ឱ្យ គជប មានភារកិច្ចកាត់សេចក្តីលើបណ្តឹងនានាដែលបុគ្គល ឬគណបក្សបានប្រព្រឹត្តល្មើសក្នុងដំណើរការបោះឆ្នោត ប៉ុន្តែសេចក្តីសំរេចរបស់ គជប ពុំអាចអនុវត្តមានប្រសិទ្ធភាពទៅលើបុគ្គលដែលប្រព្រឹត្តល្មើសបានឡើយ ដូចជាករណីរំលោភច្បាប់កើតឡើងក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ២០០៣ នៅក្នុងខេត្តកំពង់ចាម និងក្រុងកែប គជប សំរេចផាកពិន័យ៥លានរៀលរហូតមកដល់ពេលនេះនៅពុំទាន់អនុវត្តបាន ។ គជប បានស្នើសុំទៅក្រសួងយុត្តិធមិ ហើយក្រសួងយុត្តិធមិផ្តល់យោបល់ឱ្យប្តឹងទៅតុលាការខេត្ត-ក្រុងដែលបានកើតហេតុ ពេល គជប ប្តឹងតុលាការ តុលារការឆ្លើយថា គ្មានសមត្ថកិច្ចអនុវត្តន៏សេចក្តីសំរេចរបស់ គជប ទេ គឺគាត់មានសមត្ថកិច្ចអនុវត្តន៏តែសាលក្រម ។ ប្រសិនបើគ្មានវិធានការពិន័យលើបុគ្គលរំលោភច្បាប់ទេនោះ នាពេលខាងមុខបញ្ហាធ្ងន់ធ្ងរអំពីការប្រព្រឹត្តិបទល្មើសនៅតែកើតមានឡើង ។ ដើម្បីជួយសំរាលការលំបាកដល់ គជប ក្នុងនាមឯកឧត្តមផ្ទាល់ សូមអំពាវនាវដល់គណបក្សនយោបាយ និងប្រជារាស្ត្រដែលមានឧត្តមគតិចំពោះវាសនាប្រទេសជាតិ សូមមេត្តាកុំឆ្លៀតឱកាស ទោះក្នុងរូបភាពណាក៏ដោយ ចែកអំណោយ ឬបាតុភូតផ្សេងៗក្នុង

ពេលដំណើរការបោះឆ្នោត ជាពិសេសអំពើហិង្សាក្នុងយុទ្ធសាស្ត្រដណ្តើមជ័យជំនះ ហើយរួបរួមគ្នា កសាងវប្បធម៌មួយដ៏រុងរឿងដែលឈរលើគោលនយោបាយត្រឹមត្រូវ និងប្រជាប្រិយភាពរបស់គណបក្សនីមួយៗដើម្បីទទួលលទ្ធផលបានជោគជ័យទាំងផ្លូវច្បាប់ និងផ្លូវសង្គមក្រោមបន្ទាត់នៃច្បាប់ដែលបានកំណត់ ។

ឯកឧត្តមបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចប្រជុំ ខប់សែលឡឹមនេះ ព្រោះតាមរយៈខប់សែលឡឹមនេះនឹងជួយដល់ គជប អំពីចំណុចខ្វះខាតក្នុងការអនុវត្តន៍ការងាររបស់ខ្លួន ហើយក៏ជួយបញ្ជាក់ដល់មជ្ឈដ្ឋានទូទៅ ជាពិសេសប្រជារាស្ត្រដែលមិនទាន់យល់អំពីប្រយោជន៍នៃការបោះឆ្នោតឱ្យយល់អំពីតម្លៃ និងសារៈសំខាន់ដែលកើតចេញពីការបោះឆ្នោត ហើយមានឆន្ទៈបំពេញកាតព្វកិច្ចនេះឱ្យបានគ្រប់ៗគ្នា ។

ឯកឧត្តមបានអំពាវនាវដល់គ្រប់អង្គការជាតិ និងអន្តរជាតិ ដែលមានមូលនិធិ ហើយមានគោលការណ៍លើកស្ទួយលទ្ធិប្រជាធិបតេយ្យ មេត្តាជួយរៀបចំវេទិកា ឬកិច្ចប្រជុំរបៀបនេះឱ្យបានច្រើនដើម្បីឱ្យ គជប បានទទួលនូវអនុសាសន៍សំរាប់រៀបចំដំណើរការការងារបោះឆ្នោតឱ្យកាន់តែល្អប្រសើរឡើង និងទទួលបានជោគជ័យត្រចះត្រចង់នាពេលអនាគត ។

លោក **ឌិក សើរី សោភក្តិ** បានថ្លែងអំណរគុណចំពោះឯកឧត្តមអគ្គលេខាធិការរង គជប ដែលបានជំរាបជូនសមាជិកនូវស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតសំរាប់រយៈពេល៣ឆ្នាំខាងមុខនេះយ៉ាងក្បោះក្បាយ ។

## ៥. មតិរបស់សមាជិកអង្គប្រជុំឆ្លើយតបទៅនឹងបទបង្ហាញរបស់ឯកឧត្តមអគ្គលេខាធិការរង និងការពិភាក្សាអំពីរបៀប វារៈជាយុទ្ធសាស្ត្ររបស់ "ខប់សែល-COPCEL" ក្នុងពេលបីឆ្នាំខាងមុខ

លោក **យង់ គិមអេង** ប្រធានសមាគមយុវជនខ្មែរ បានលើកឡើងនូវបញ្ហា៣ចំណុច។ លោកពុំមានកង្វល់អ្វីទេ ចំពោះការបោះឆ្នោតព្រឹទ្ធសភា ព្រោះមានតែតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់តែប៉ុណ្ណោះជាអ្នកទៅបោះឆ្នោត ហើយអ្វីដែលលោកធ្វើការចាប់អារម្មណ៍ គឺថាកន្លងមក យើងមានគណៈកម្មការសន្តិសុខសំរាប់ការបោះឆ្នោត ប៉ុន្តែគណៈកម្មការសន្តិសុខនេះ គជប ហាក់ដូចជាគ្មានអំណាចទៅដឹកនាំគណៈកម្មការនោះទេ ។ នៅក្នុងការកំណត់អំពីបទដ្ឋាន អប្បបរិមា សរុបសំរាប់ការបោះឆ្នោត ដែលគេបានរៀបចំជាសាកល គេត្រូវឱ្យគណៈកម្មការត្រូវតែស្ថិតនៅក្រោមសមាសភាពនៃ គជប ឬស្ថិតនៅក្រោមការដឹកនាំរបស់ គជប ដោយផ្ទាល់ ហើយគេមានទាំងកំណត់ទៀតថា បើសិនជាស្ថាប័នដែលពាក់ព័ន្ធណាមួយខកខានមិនបានចូលរួមប្រជុំគេត្រូវមានទណ្ឌកម្មមានពិន័យ ពីព្រោះថានេះ គឺជាស្ថានការណ៍របស់ជាតិ ជាព្រឹត្តការណ៍ជាតិដែលត្រូវទទួលខុសត្រូវ ហើយគេត្រូវតែប្រមូលកំលាំងសរុបគ្រប់ស្ថាប័នរបស់ជាតិដើម្បីជំរុញឱ្យការបោះឆ្នោតនេះប្រព្រឹត្តដោយសេរី និងយុត្តិធម៌។ លោកសូមតាមរយៈខប់សែលនេះឱ្យ គជប ប្រកាន់អព្យាក្រឹតភាពកុំឱ្យក្លាយជាខ្លាក្រដាសដូចគេវាយតម្លៃកន្លងមក ។ បើអគ្គបញ្ជាការ ឬក៏អគ្គស្នងការនគរបាលជាតិ គាត់មិនសហការទេ គជប ក៏មិនដឹងធ្វើយ៉ាងម៉េចដែរ អញ្ចឹងគួរតែមានការចែងឱ្យច្បាស់ពីបញ្ហានេះ ។

បញ្ហាទី ២ ចំពោះសមភាពរឿងប្រព័ន្ធផ្សព្វផ្សាយ យើងចង់ឱ្យមានភាពប្រសើរ សំរាប់គំរូវការប្រជាធិបតេយ្យនៅស្រុកខ្មែរយើងដែរ ហើយនិងធានានូវភាពសេរីយុត្តិធម៌ពិតប្រាកដ គួរតែប្រព័ន្ធផ្សព្វផ្សាយ ធ្វើយ៉ាងណាឱ្យមានការបើកទូលាយដល់គ្រប់គណបក្សនយោបាយដែលអាចនឹងធ្វើការឃោសនា ឬក៏ចែកចាយព័ត៌មានពីគណបក្សនយោបាយរបស់ខ្លួនទៅប្រជា

ពលរដ្ឋបានងាយស្រួលផង ទោះបីថាតាមរូបភាពជួលក៏ដោយ។ បើសិនណាប្រព័ន្ធផ្សព្វផ្សាយណាដែលចង់ជួលទៅឱ្យគណបក្សនយោបាយមួយៗ សុំដាក់កំណត់ថា យកតំលៃប៉ុន្មាន ហើយផ្សាយឱ្យគេដឹងព្វទាំងអស់គ្នា ដើម្បីឱ្យគណបក្សនយោបាយនោះអាចនឹងមានឱកាសរកប្រព័ន្ធផ្សព្វផ្សាយឯកជនបាន ។ ដោយឡែក ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋយើង គឺថាការផ្សព្វផ្សាយព័ត៌មានពីការបោះឆ្នោតច្រើនតែយឺតយ៉ាវ មិនដឹងថា ខាងទំនាក់ទំនងរបស់ គជប ជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋយើងនេះនៅមានកំរិត និង បញ្ហាយ៉ាងម៉េចទេ បានជាយឺតយ៉ាវបែបនេះ ជួនកាលការចុះឈ្មោះត្រូវប្រព្រឹត្តទៅតាំងពីខែមុន ទើបចាក់ផ្សាយវាគួរតែផ្សាយឱ្យបានមុនយ៉ាងហោចណាស់ក៏ ២-៣ខែដែរ ដើម្បីឱ្យប្រជាពលរដ្ឋត្រៀមលក្ខណៈ ឬក៏យល់ថាការបោះឆ្នោតវាមិនមែនជាចំណាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ នេះជាបញ្ហាដែលយើងគួរតែឱ្យ គជប ធ្វើការជំរុញបញ្ហានេះ។ ចំពោះការចុះអត្តសញ្ញាណប័ណ្ណ លោកបានថ្លែងថា តាំងពីឆ្នាំ១៩៩៣ មកដល់ឥឡូវនេះ យើងមិនទាន់កំណត់អត្តសញ្ញាណថា អ្នកណាជាខ្មែរច្បាស់លាស់ រស់នៅក្នុងស្រុកខ្មែរមិនដឹងខ្លួនឯងថាជាស្អី នេះគួរឱ្យខ្មាស់គេណាស់ ។ ការងារអត្តសញ្ញាណប័ណ្ណ បើយើងជំរុញឱ្យវាបានឆាប់ វានឹងចេញឆាប់ ហើយវាមិនគួរមានភាពយឺតយ៉ាវសោះ។ ការណ៍អត់មានអត្តសញ្ញាប័ណ្ណណសំគាល់ថាខ្លួនជាខ្មែរ មិនដឹងទៅប្រាប់អ្នកណាថាខ្លួនឯងជាខ្មែរទេ។ ហើយចំពោះប្រជាជាតិមួយ តើយើងនិយាយពីរឿងមោទនភាពជាតិដូចម្តេចកើត បើយើងមិនទាន់មានស្អីសំគាល់ថាខ្លួនឯងជាខ្មែរផងនោះ ។ ហើយបញ្ហាចុងក្រោយ គឺពាក់ព័ន្ធនឹងរឿងគណបក្សនយោបាយមួយៗ ឥឡូវមានគណបក្សចូលរួមច្រើន ប៉ុន្តែគណបក្សទាំងអស់សុទ្ធតែលើកឡើងអំពីរឿងថា គណនេយ្យភាព តម្លាភាព តែមិនដែលឃើញមានគណបក្សណាមួយធ្វើសវនកម្មទេ អញ្ចឹងគួរតែតួអង្គដែលពាក់ព័ន្ធការបោះឆ្នោតអប់រំប្រជាពលរដ្ឋ ឬផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីគណបក្សណាដែលមិនធ្វើសវនកម្ម មិនគួរឱ្យប្រជាពលរដ្ឋបោះឆ្នោតឱ្យទេ ព្រោះបើបោះឆ្នោតឱ្យគាត់ប្រហែលពុករលួយ ហើយ ។

លោក **កុយ ច័ន្ទដារិទ្ធ** អ្នកសំរបសំរួលផ្នែកព័ត៌មាននៃគណៈកម្មាធិការខុមហ្វ្រែលមានចំណាប់អារម្មណ៍លើរបាយការណ៍របស់ឯកឧត្តមអគ្គលេខាធិការរង ត្រង់ការកាត់ក្តីដែលឯកឧត្តមបានមានប្រសាសន៍ថា មានការផាកពិន័យ៥លានរៀល ហើយរហូតដល់ពេលនេះ មិនបានសំរេចទៅតាមអ្វីដែល គជប បានសំរេច រហូតដល់តុលាការពុំហ៊ានចាត់វិធានការជុំវិញបញ្ហានេះទៀត ។ លោកបានសួរថាតើ គជប មានវិធានការយ៉ាងដូចម្តេច សំរាប់ការបោះឆ្នោតក្រោយៗទៀត ឬមួយក៏រក្សាទុករចនាសម្ព័ន្ធនេះដដែល ឬមួយក៏មានការផ្លាស់ប្តូរ ហើយបើតាមលោកនៅចាំការបោះឆ្នោតកន្លងមកគឺថា អង្គការសង្គមស៊ីវិលបានជូនជាអនុសាសន៍ជាច្រើនជុំវិញការរៀបចំឱ្យមានជាស្ថាប័នមួយឯករាជ្យសំរាប់ធ្វើការកាត់ក្តីបោះឆ្នោតនេះ ដោយយើងមានឧទាហរណ៍ដូចជាឱ្យប្រគល់ទៅស្ថាប័នតុលាការតែម្តងសំរាប់ចាត់វិធានការក្នុងការកាត់ក្តីការបោះឆ្នោតនេះដែរ។

លោក **លី សុធារ៉ាយុត្តិ** មន្ត្រីកម្មវិធីនៃវិទ្យាស្ថាន NDI បានបញ្ចេញចំណាប់អារម្មណ៍៣ចំណុចៈ ទី១ គឺលទ្ធផលនៃការបោះឆ្នោត ទី ២ គឺប្រព័ន្ធផ្សព្វផ្សាយ និងទី៣ គឺបញ្ហាអត្តសញ្ញាណប័ណ្ណ។

- ទី១ លទ្ធផលនៃការបោះឆ្នោត លោកបានស្តាប់ ឯកឧត្តមអគ្គលេខាធិការរងមានប្រសាសន៍ថា ក្រោយពីមានការបោះឆ្នោតយើងឃើញថា គណបក្សចាញ់ឆ្នោតមួយចំនួនមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត នេះជាការពិតមែន បន្ទាប់ពីយើងបោះឆ្នោតដែលរៀបចំដោយខ្លួនឯងតាំងពីឆ្នាំ១៩៩៨។ មានមនុស្សមួយចំនួនធំបានសង្កេតឃើញថា លទ្ធផលនៃការបោះឆ្នោតមិនទាន់ទាំងបានប្រកាសដោយ គជប ជាផ្លូវការផង ក៏ប៉ុន្តែមានគណបក្សមួយចំនួនបានប្រកាសរួចហើយថា គណបក្សនេះបានចំនួនប៉ុណ្ណោះ គណបក្សនោះបានចំនួនប៉ុណ្ណោះ ហើយការណ៍ដែលប្រកាសដោយគ្មានការអនុញ្ញាតពី គជប នេះហើយវាធ្វើឱ្យមានចលាចលនៅក្នុងសង្គម

វាឈានទៅរកការមិនទទួលស្គាល់ពីគណបក្សមួយចំនួន ដែលគាត់គិតថា លទ្ធផលនៃការបោះឆ្នោត គឺអាចដឹងមុនរួចហើយដោយមិនទាន់មានការប្រកាសជាផ្លូវការពី គជប នៅឡើយផង អញ្ចឹងវាធ្វើឱ្យមានការជាប់គាំងផ្នែកនយោបាយជារឿយៗ ។ ដោយសារតែមូលហេតុនេះ ថាតើ គជប ស្ថាប័នឯករាជ្យដែលរៀបចំការបោះឆ្នោតមានអំណាចគ្រប់គ្រាន់ក្នុងការរាំងទប់នូវការប្រកាសលទ្ធផលនៃការបោះឆ្នោតមុន គជប ប្រកាសដែរឬទេ? ដើម្បីកុំឱ្យមានតទៅទៀត ព្រោះយើងនៅមានការបោះឆ្នោតជាហូរហែទៀតរៀងរាល់៥ឆ្នាំម្តង ។

- ទី២ យើងសង្កេតឃើញថា ប្រព័ន្ធផ្សព្វផ្សាយ គឺជាចំណុចរសើបមួយដែលរមែងទទួលការរិះគន់ពីមជ្ឈដ្ឋានទូទៅនៅក្នុងសង្គម។ ប្រព័ន្ធផ្សព្វផ្សាយហាក់ដូចជាមានការបែងចែកជាក្រុមៗ ព្រោះមានលំអៀងទៅរកគណបក្សនេះ គណបក្សនោះ ឃើញថាគណបក្សមួយចំនួនដែលចូលរួមក្នុងការបោះឆ្នោត ពិបាកនឹងស្វះស្វែងរកឱកាសក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយណាស់។ ជាពិសេសក្នុងយុទ្ធនាការឃោសនា តែបើគណបក្សណាដែលមានអំណាចខ្លាំង គឺអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបានច្រើនជាគណបក្សមួយផ្សេងទៀត។ តើ គជប អាចគ្រប់គ្រងស្ថានភាពនេះបានដែរឬទេ? តើអាចរកយុទ្ធសាស្ត្រណាផ្សេងទៀតដើម្បីឱ្យឱកាសនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមានភាពស្មើៗគ្នារវាងគណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតដែរឬទេ?

- ទី៣ បញ្ហាអត្តសញ្ញាណប័ណ្ណ បើតាមស្តាប់ទៅឃើញថា ឱកាសការចែកចាយអត្តសញ្ញាណប័ណ្ណ ទើបមកដល់ពេលនេះគឺសឹងតែ៣ឆ្នាំហើយ គឺបានត្រឹមតែ ៧0%ប៉ុណ្ណោះ លោកឆ្ងល់ថាហេតុអ្វីបានជាស៊ីពេលអីដល់រាប់ឆ្នាំយ៉ាងហ្នឹង ។ នៅតំបន់ខ្លះ ដូចជានៅសង្កាត់មួយនៅខ័ណ្ឌឬស្សីកែវ រហូតដល់អត្តសញ្ញាណប័ណ្ណបានចែកដល់ក្រុមប្រឹក្សា-សង្កាត់ហើយ ប៉ុន្តែម្ចាស់អត្តសញ្ញាណប័ណ្ណនៅតែមិនទាន់បានទទួលអត្តសញ្ញាណប័ណ្ណទៀតរហូតដល់ថ្ងៃនេះ ហើយមានអ្នកខ្លះបានស្លាប់ទាំងមិនទាន់បានអត្តសញ្ញាណប័ណ្ណផង ហើយនេះជាបញ្ហាធំណាស់ ។ ដូច្នេះលោក សូមតំណាងក្រសួងមហាផ្ទៃមេត្តាជួយបកស្រាយអំពីនីតិវិធីនៃការផ្តល់អត្តសញ្ញាណប័ណ្ណ វាពិបាកដល់កំរិតណាដែលបណ្តាលឱ្យមានការយឺតយ៉ាងបែបនេះ ព្រោះបញ្ហានេះមានទាក់ទងនឹងការចុះឈ្មោះអ្នកបោះឆ្នោត។

មុននឹងជូនវេទិកាទៅតំណាងក្រសួងមហាផ្ទៃ លោក **ឱក សេរី សោភក្តិ៍** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅតាមរយៈឯកឧត្តម ឧត្តមសេនីយ៍ទោ **ណុប ស៊ីណូ** ជូនចំពោះឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡងឌី** អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិដែលបានគាំទ្រដល់យន្តការខប់សែលតាំងពីដំណាក់កាលទី១រហូតមកដល់ដំណាក់កាលទី២ ជាក់ស្តែងដូចជាការអនុញ្ញាតឱ្យតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិមកចូលរួមក្នុងយន្តការនេះមិនដែលខកខានឡើយ។

ឯកឧត្តម ឧត្តមសេនីយ៍ទោ **ណុប ស៊ីណូ** តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃបានសំដែងនូវអំណរគុណដល់យន្តការខប់សែលដែលជាយន្តការមួយដើម្បីបង្ការទំនាស់ក្នុងការបោះឆ្នោត ។ ឯកឧត្តមមានក្តីរីករាយនឹងឆ្លើយសំណួររបស់សមាជិកអង្គប្រជុំដែលទាក់ទងនឹងការងារសន្តិសុខ និងការធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ។ ឯកឧត្តមសំណូមពរថា បើសិនជាមានសំណួរសូមលើកឱ្យចំបញ្ហាងាយស្រួលឯកឧត្តមឆ្លើយជូន។ ក្រសួងមហាផ្ទៃតែងតែបានសហការជាមួយ គជប ក្នុងការរៀបចំផែនការការពារសន្តិសុខក្នុងដំណើរការបោះឆ្នោត។ រីឯបញ្ហាធ្វើអត្តសញ្ញាណប័ណ្ណ វាលំបាកណាស់ក្រោយពីយើងមានសង្គ្រាមមកវាបាត់អស់នូវអ្វីដែលជាឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រជាពលរដ្ឋយើង ។ មានក្រុមហ៊ុនពីរដែលទទួលម៉ៅការបោះពុម្ពអត្តសញ្ញាណប័ណ្ណក្នុងគំរោងចំនួន៥លានសន្លឹក គឺក្រុមហ៊ុន ឈុន ហុង ចំនួន៤លានសន្លឹក និងក្រុមហ៊ុន ហ្គូលខ៊ៀនឆាយណា ១លានសន្លឹក ហើយរឿងនេះមិនមែនជារឿងលាក់ការណ៍អីទេ តែវាជារឿងមួយដែលត្រូវតែឱ្យមានតម្លាភាព ឱ្យយល់ពីបញ្ហាលំបាក ។ តាមស្ថិតិដែល

ឯកឧត្តមបានស្រង់នេះគឺមានជាង៧លាននាក់ដែលមានសិទ្ធិបោះឆ្នោត ប៉ុន្តែយើងចាប់ដំណើរការ៣-៤ឆ្នាំមុនដែលយើងធ្វើអត្តសញ្ញាណប័ណ្ណនេះ យើងបានគោលការណ៍ដែល សជណ កំណត់ឱ្យយើងធ្វើនេះចំនួនតែ៥លានសន្លឹក តែមកទល់ថ្ងៃនេះ យើងបានសំរេចជោគជ័យបានជាង៦លានសន្លឹក។ ដូច្នេះបានន័យថា វាលើសពីផែនការទៅទៀតផង។ ការងារនីមួយៗវាមានផែនការជាដំណាក់ៗ ឥឡូវឈានដល់ដំណាក់កាលទី២ ដែលមានការអនុញ្ញាតឱ្យផលិត១លានទៀត បើប្រៀបធៀបនឹងស្ថិតិប្រជាពលរដ្ឋដូចជាមិនទាន់គ្រប់ទេដែលមានរហូតទៅដល់ជាង៧លានឯណោះ ដូច្នេះទាល់តែផែនការជាង២លានទៀតទើបបានគ្រប់ ។

ទោះបីយ៉ាងណាក៏ដោយ ឯកឧត្តមជឿថានឹងអាចផ្តល់ជូនប្រជាពលរដ្ឋបាន៩០ភាគរយដែរ ។ឯកឧត្តមបញ្ជាក់ថា ហេតុអ្វីមិនអាចធ្វើបាន ១០០% បញ្ហានៅត្រង់ថា តំបន់ខ្លះពិបាកណាស់ដែលយើងឱ្យជំនាញចុះទៅផ្ទាល់ ដូចជាខេត្តរតនគិរី មណ្ឌលគិរី ស្រុកខ្លះយើងដើរ៧យប់ ៧ថ្ងៃបានទៅដល់ ហើយត្រូវការសំភារៈ ឧបករណ៍ផលិតអត្តសញ្ញាណប័ណ្ណ។ ប្រជាពលរដ្ឋខ្លះយើងទៅរកគាត់មិនដែលបានជួបទេ ព្រោះលោកអត់នៅផ្ទះជាប់ទៅប្រកបរបរចិញ្ចឹមជីវិតរបស់គាត់ជួនកាលមួយខែទៅពីរខែមិនទាន់មកម្តងផង។ ដូច្នេះហើយបានជាមិនអាចសំរេចបាន១០០ភាគរយតាមការចង់បាននោះ។

ចំពោះសំណួរ ហេតុអ្វីក៏មានការយឺតយ៉ាវក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណ ឯកឧត្តមបានជំរាបថា យន្តការផ្តល់អត្តសញ្ញាណប័ណ្ណគឺប្រជាពលរដ្ឋលោកទៅសុំធ្វើអត្តសញ្ញាណប័ណ្ណ មានកន្លែងគេសំភាសន៏ គេថតរូប គេបញ្ចូលក្នុងកុំព្យូទ័រ ហើយបានធ្វើឯកសាររៀបចំបញ្ជូនមកក្រសួងដើម្បីផលិត ពេលផលិតហើយបានផ្ញើត្រឡប់ទៅវិញដើម្បីដាក់ជូនអភិបាលខេត្ត-ក្រុងចុះហត្ថលេខា ត្រង់ចំណុចនេះក៏មានការពិបាកដែរ ព្រោះក្នុងអនុក្រឹត្យអត់មានចែងឱ្យលោកអភិបាលរងទីមួយមានសិទ្ធិចុះហត្ថលេខាបានទេ ទាល់តែអភិបាលខេត្តឬអភិបាលក្រុងតែម្តង ជួនកាលលោកជាប់រវល់ ដាក់ទៅមួយម៉ឺនសន្លឹក ចុះហត្ថលេខាបានតែមួយពាន់ ឬពីរពាន់ ។ ក្នុងនាមឯកឧត្តមផ្ទាល់ដែលទទួលខុសត្រូវលើការងារអត្តសញ្ញាណប័ណ្ណ និងការងារស្ថិតិនេះបានសន្យាថា នឹងខំប្រឹងធ្វើយ៉ាងណាឱ្យការណ៏នេះកាន់តែមានភាពកាន់តែប្រសើរឡើង ហើយសូមផ្តល់ព័ត៌មានជាក់ស្តែងចំពោះការយកលុយកាក់ ឯកឧត្តមនឹងធ្វើការតាមដាន ព្រោះឯកឧត្តមមានតួនាទីជាអ្នកការពារ និងបំរើប្រជាពលរដ្ឋ ហើយនេះជាទស្សនៈគោលរបស់នគរបាលជាតិយើង ប៉ុន្តែបើព័ត៌មាននោះមិនច្បាស់លាស់ ឬគ្រាន់តែឮពាក្យចចាមអារាមនោះវាពិបាកដោះស្រាយណាស់។

ឯកឧត្តម **សុកុលៈ ទីប៉ោ** បានឆ្លើយតបទៅនឹងសំណួរអំពីប្រព័ន្ធផ្សព្វផ្សាយថា ប្រព័ន្ធផ្សព្វផ្សាយបច្ចុប្បន្នរបស់រដ្ឋហាក់ដូចជាមានតិច ភាគច្រើនជាប្រព័ន្ធផ្សព្វផ្សាយរបស់ឯកជន។ កាលណាគ្រប់គ្រងដោយឯកជន គឺគេគិតពីផលចំណេញហើយ ហើយ គជប ខំប្រឹងធ្វើការងារតាមផែនការរបស់ខ្លួនតាមប្រក្រតិទិនកំណត់ថា ក្នុងរយៈពេលប៉ុន្មានមុនការបោះឆ្នោតត្រូវផ្សព្វផ្សាយអំពីការចុះឈ្មោះ ឬក៏អំពីនីតិវិធីផ្សេងៗ គជប ខិតខំប្រឹងប្រែងតាមប្រក្រតិទិនរបស់ខ្លួនមិនឱ្យខុសទេ ។ ហើយម៉្យាងទៀតនោះ ការគោលនយោបាយគណបក្សនីមួយៗ គជប បានរៀបចំកម្មវិធីមួយហៅថា កម្មវិធីស្មើភាពដែលរៀបចំជាតុមូល ហើយអញ្ជើញគ្រប់គណបក្សទាំងអស់មកចូលរួម ហើយបានចាប់ឆ្នោតយកលេខរៀងថាតើ គណបក្សណាមួយគាត់នឹងចូលមកឆ្លើយ និងចូលមកពិភាក្សាអំពីគោលនយោបាយរបស់គាត់ដើម្បីផ្សព្វផ្សាយតាមទូរទស្សន៍ ហើយមានពេលកំណត់ក្នុងរយៈពេលស្មើៗគ្នា ។បញ្ហាមួយទៀតគឺរឿងកាត់ក្តីថាតើ គជប មានវិធានការយ៉ាងណាដើម្បីរៀបចំវិធីសំរាប់កាត់ក្តី មកដល់សព្វថ្ងៃនេះនិយាយឱ្យត្រង់ហាក់ដូចជានៅ មានបញ្ហា ប៉ុន្តែ គជប កំពុងរៀបចំសុំគោលការណ៏ទៅក្រុមប្រឹក្សាធម្មនុញ្ញដើម្បីលោកណែនាំពីនីតិវិធី ឬមួយសុំទៅរាជរដ្ឋាភិបាលថា

ដើម្បីរកនីតិវិធីណាឱ្យ គជប មានអំណាចអនុវត្តសេចក្តីសំរេចរបស់ខ្លួន ប៉ុន្តែលទ្ធផលមិនទាន់ទទួលបានទេ ប៉ុន្តែជាគោលការណ៍ គជប បានរៀបចំរួចហើយ ។

លោក **ឪក សេរី សោភក្តិ** បានថ្លែងថា អត្តសញ្ញាណប័ណ្ណជាបញ្ហាសំខាន់ណាស់ដែលត្រូវយកចិត្តទុកដាក់ ហើយលោកបានកោតសរសើរចំពោះការប្រឹងប្រែងរបស់នគរបាលជាតិក្នុងកិច្ចការផ្តល់អត្តសញ្ញាណប័ណ្ណនេះ។ តែទោះជាយ៉ាងនេះក្តីក៏មានអត្តសញ្ញាណប័ណ្ណជាច្រើនដែលខាងនគរបាលបានធ្វើហើយត្រូវទើនៅការិយាល័យឯកឧត្តមអភិបាលខេត្ត-ក្រុងរង់ចាំការចុះហត្ថលេខា។ ភាពយឺតយ៉ាវនេះ គឺជាមូលហេតុនាំឱ្យការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋមិនបានលឿនដូចបំណង។

លោកបណ្ឌិត **ហង្ស ពុទ្ធា** នាយកប្រតិបត្តិគណៈកម្មាធិការនិកហ្វិច បានជំរាបជូនអង្គប្រជុំ៤ចំណុចៈ

**ទី១** លោកសង្កេតឃើញថា បណ្តាញសង្កេតការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលតែងមានបញ្ហាជាមួយនឹងមន្ត្រីរៀបចំការបោះឆ្នោតតាមគ្រប់លំដាប់ថ្នាក់។ លោកបានសំណូមពរថា ជាការល្អនៅពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេស គជប គួរហៅអ្នកសង្កេតការណ៍ឱ្យបានចូលរួមយ៉ាងតិចណាស់ ៥នាក់ពីអង្គការសង្គមស៊ីវិល នីមួយៗ ព្រោះជួលកាលមានការអញ្ជើញចូលរួមតែម្នាក់ប៉ុណ្ណោះ។ លោកយល់ថា ការងារបច្ចេកទេសអាចយល់ដឹងខុសគ្នា ហើយធ្វើឱ្យមានបញ្ហានៅពេលដែលដំណើរការការបោះឆ្នោត។

**ទី២** លោកសូមធ្វើការអំពាវនាវចំពោះអង្គការមិនមែនរដ្ឋាភិបាល គជប ឬក៏ស្ថាប័នណាក៏ដោយ ពេលដែលអប់រំប្រជាពលរដ្ឋទោះបីពាក់ព័ន្ធនឹងការបោះឆ្នោតក្តី មិនពាក់ព័ន្ធក្តីគួរតែបញ្ចូលសារមួយទៅឱ្យប្រជាពលរដ្ឋស្តីអំពីនិន្នាការជ្រុលនិយមដែលកើតមានឡើងនៅជនបទដាច់ស្រយាល បានន័យថា ទប់ស្កាត់នូវពាក្យស្លោកដែលថា **"ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី"** ។

**ទី៣** នាបច្ចុប្បន្ននេះ លោកកំពុងតែធ្វើការងារអប់រំប្រជាពលរដ្ឋស្តីអំពីដំណើរវិមជ្ឈការនៅកម្ពុជា ក្នុងនោះលោកបានទទួលព័ត៌មានពី៣ខេត្ត ថាបច្ចុប្បន្ននេះមានជនជាតិវៀតណាមដែលកំពុងតែរស់នៅលើទឹកដីកម្ពុជាបានសុំចុះសំបុត្រកំណើតឱ្យកូនរបស់គាត់ដោយសំអាងថា កូនរបស់ពួកគាត់កើតនៅស្រុកខ្មែរ។ ដូច្នេះពួកគាត់ទៅសុំចុះសំបុត្រកំណើតនៅសាលាឃុំ ហើយបញ្ហានេះលោកយល់ថា ក្រសួងមហាផ្ទៃគួរតែធ្វើការបកស្រាយឱ្យបានច្បាស់លាស់ ព្រោះជនជាតិវៀតណាមទាំងនោះបាននិយាយថា បើគាត់យកកូនគាត់ទៅចុះសំបុត្រកំណើតនៅប្រទេសវៀតណាមក៏ប្រទេសវៀតណាមអត់ទទួលស្គាល់ដែរ។

**ទី៤** ពាក់ព័ន្ធទៅនឹងបញ្ហាព័ត៌មាន កន្លងមកយើងតែងតែគិតថា នៅជនបទដាច់ស្រយាលពិបាកនឹងទទួលព័ត៌មានដោយសារពុំមានមធ្យោបាយគ្រប់គ្រាន់ និងទៅមិនដល់ ។ ត្រង់ចំណុចនេះលោកបានបញ្ជាក់ថា ម្សិលម៉ិញនេះលោកបានទៅចូលរួមធ្វើចំណាប់អារម្មណ៍ខ្លីមួយនៅក្នុងសិក្ខាសាលាដែលរៀបចំឡើងដោយអង្គការ Equal Access ដែលទទួលជំនួយពី USAID ក្នុងនេះគឺ Equal Access នឹងរៀបចំប្រព័ន្ធផ្សព្វផ្សាយមួយពីផ្កាយរណប បច្ចុប្បន្នមានវិទ្យុចំនួន ៣០គ្រឿងហើយដែលប្រើដោយកាំរស្មី និងធ្វើការដាក់ជូនប្រើប្រាស់នៅតាមភូមិនេះគឺជាព័ត៌មានមួយដែលល្អសំរាប់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល។ ប៉ុន្តែលោកស្រីតំណាងខាង Equal Access បាននិយាយថា គាត់ផ្សាយតែពីរឿងការជួញដូរស្ត្រី ហើយនិងបញ្ហាទុកលំបាកនៃការកើតជំងឺអេដស៍នៅប្រទេសកម្ពុជា ប៉ុន្តែលោកគិតថា ជួនកាលព័ត៌មានខ្លះយើងអាចផ្សព្វផ្សាយតាមរយៈរលកធាតុអាកាសនេះដែរ ប៉ុន្តែទាមទារឱ្យព័ត៌មានមានភាពអព្យាក្រឹត ហើយយើងអាចទាក់ទងជាមួយអង្គការនេះដើម្បីឱ្យជួយផ្សព្វផ្សាយព័ត៌មាននូវចំណុចណាដែលយើងគិតថា ព័ត៌មាននោះពុំបានទៅដល់ជនបទដាច់ស្រយាល ។

ឯកឧត្តម **អ៊ុក ភូរិ** ប្រធានគណបក្សប្រជាធិបតេយ្យខ្មែរ បានលើកឡើងនូវចំណាប់អារម្មណ៍ដូចខាងក្រោមៈ

ទាក់ទងនឹងអត្តសញ្ញាណប័ណ្ណ ឯកឧត្តមបានចាប់អារម្មណ៍ក្រោយពីស្តាប់ឯកឧត្តម ឧត្តមសេនីយលើកឡើង ក៏ដូចជាវាគ្មិនមួយចំនួនថាវាមានចំណុចរសើបជាច្រើន ដូចជាការយកលុយកាក់ជាដើម។ លោកឧត្តមសេនីយ៍បានលើកឡើងតែពីភាពយឺតយ៉ាវនៃការចុះហត្ថលេខារបស់ឯកឧត្តម អភិបាលខេត្ត-ក្រុង ដើម្បីផ្តល់សុពលភាពទៅលើអត្តសញ្ញាណប័ណ្ណនោះ។ ឯកឧត្តមផ្ទាល់ យល់ថានេះមិនចោទជាបញ្ហាច្រើនទេ ឯបញ្ហាចោទ គឺត្រង់ចំណុចដែលគ្មានលុយឱ្យគឺមិនបានទទួលអត្តសញ្ញាណប័ណ្ណទេ ត្រង់ចំណុចនេះឯកឧត្តមបានជំរាបសមាជិកអង្គប្រជុំថា ពេលខ្លះមានការយកលុយលើសពី២០ដុល្លារទៅទៀត ។ ហើយនេះជាអំពើមួយដែលមិនគប្បីនិងធ្វើឱ្យប្រជាពលរដ្ឋក្រីក្ររបស់យើងលោកអត់ការងារធ្វើ មិនមែនត្រឹមតែរឿងបោះឆ្នោតមួយមុខទេ។ ហើយចំណែកឯប្រជាពលរដ្ឋក៏គាត់មានចំណុចខ្សោយរបស់គាត់ដែរ តែធ្វើយ៉ាងម៉េចបើគាត់រវល់រកស៊ីចិញ្ចឹមជីវិត។ ដូច្នេះយើងសុខចិត្តផ្សព្វផ្សាយឱ្យច្រើនដង ថាហេតុអ្វីប្រជាពលរដ្ឋខ្មែរដើរសុខចិត្តអត់អត្តសញ្ញាណប័ណ្ណ ហើយអន្តោប្រវេសន៍មួយចំនួនបែរជាមានទៅវិញ ហើយចំណុចមួយទៀតដែលឯកឧត្តមចាប់អារម្មណ៍ គឺអត្តសញ្ញាប័ណ្ណ និងសៀវភៅគ្រួសារមិនស៊ីគ្នា ដូចជាខុសឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើតជាដើម។ ដូច្នេះ ខាងសមត្ថកិច្ចគួរធ្វើឱ្យហ្មត់ចត់ និង ម៉ឺងម៉ាត់ដើម្បីជៀសវាងការខុសឆ្គងបច្ចេកទេសរបៀបនេះទៀត។ មានចំណុច១ទៀតដែលឯកឧត្តមបានបានសង្កេតឃើញគ្រប់ពេលបោះឆ្នោតទាំងអស់ គឺតែងធ្វើច្បាប់មានលក្ខណៈតក់ក្រហល់ ដូចជាច្បាប់បោះឆ្នោតព្រឹទ្ធសភាជាដើម។ ឯកឧត្តមបានបន្ថែមថា ការតាក់តែងច្បាប់ ឬ ធ្វើវិសោធនកម្មមាត្រាច្បាប់ណាមួយត្រូវធ្វើពីចំងាយ ដើម្បីឱ្យមានការចូលរួមចំណែកឱ្យគេពេញចិត្តពេញថ្លើមទាំងអស់គ្នា ហើយគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលផ្សេងៗ គួរត្រូវបានអញ្ជើញគេឱ្យចូលរួមផ្តល់មតិយោបល់ដើម្បីជៀសវាងបញ្ហាបោះឆ្នោត ក៏ដូចជាការមិនទទួលស្គាល់លទ្ធផលបោះឆ្នោតនៅទីបញ្ចប់។

ស្រុកយើងគ្មានអាជ្ញាសាលាដើម្បីអនុវត្តន៍ទេ ដូច្នេះសូមឱ្យខាងក្រសួងមានសមត្ថកិច្ចដែលមានទំនាក់ទំនងការងារជាមួយ គជប ព្រមទាំងតុលាការ ត្រូវសហការជាមួយគ្នាអនុវត្តការកាត់ក្តីឱ្យបានត្រឹមត្រូវ ហើយបើច្បាប់វាចន្លោះប្រហោង គជប ត្រូវសិក្សាឱ្យស៊ីជំរៅបានហ្មត់ចត់ល្អ មានភាពប្រសើរដើម្បីកុំឱ្យមានការសង្ស័យ បើនៅមានការសង្ស័យ យើងមានការលំបាកក្នុងការអនុវត្តន៍។ ឯកឧត្តមថ្លែងថា គជប បានជួយជាតិច្រើនណាស់ ហើយគណបក្សនយោបាយធំៗក៏បានជួយជាតិច្រើនដែរ ក៏ប៉ុន្តែយើងជាបងគេ យើងអ្នកធ្វើច្បាប់ តែកាលណាធ្វើខុសបន្តិចគេចោទប្រកាន់យើងហើយ ព្រោះអ្នកតូចចាំតែមើលអ្នកធំទេ។ ឯកឧត្តមផ្ទាល់មិនពេញចិត្តទេចំពោះគណបក្សធំៗដែលធ្វើច្បាប់មកសំរាប់ខ្លួនឯង បើកាលណាគេឱ្យយើងធ្វើជាបង ជាម្តាយឪពុកមើលកូន យើងគិតតែពីប្រយោជន៍របស់យើង យើងបានបាយហូបតែហូបម្នាក់ឯង តើនេះសមរម្យទេ? ឯកឧត្តមបានបន្ថែមទៀតថា គណបក្សតូចៗកើតមកមាន៥៤គណបក្ស ក្រោយមកចុះមកនៅ៣៩ ក្រោយមកចុះមកនៅ៣១ ក្រោយមក២៤ បន្តិចទៀតប្រហែលនៅសល់ក្រោម ១០ផងក៏មិនដឹង តែនេះវាជារឿងធម្មតាទេ។ ដើម្បីឱ្យគណបក្សតូចៗអាចរស់បាន អ៊ុនតាក់គេចេះធ្វើរូបមន្តមួយយ៉ាងស្រួលដើម្បីឱ្យគណបក្សតូចៗបានសន្លឹកឆ្នោត ដូចជាគណបក្ស លោកតា សឺន សាន តាមធម្មតាបើធ្វើតាមរូបមន្តដែលយើងគិតយកមធ្យម ភាគធំគាត់បានតែ២កៅអីទេ ប៉ុន្តែគាត់បានរហូតដល់១០កៅអីឯណោះ ដែលនេះជារូបមន្តបន្ធូរបន្ថយមួយឱ្យគណបក្សតូចៗ បានរស់ផង។ ដូច្នេះគណបក្សធំៗដែលគេចាត់ទុកថាជាបង ជាម្តាយឪពុក គួរគិតគូរឱ្យគណបក្សតូចៗរស់ផង កុំយករស់តែឯង។ ស្រុកអាមេរិកមានគណបក្សដំបូងជាង២០០ ហើយឥឡូវនៅសល់តែ៥ទេ តែមុននឹងគេស្លាប់ គឺគេស្លាប់ដោយអស់ចិត្ត និងឱ្យគេតស៊ូឱ្យបានយូរបន្តិចកុំសម្លាប់គ្នាដោយកើតមកហើយត្រូវស្លាប់ទៅវិញភ្លាម ដោយសាររូបមន្តមិនត្រឹមត្រូវ។ ត្រង់ចំណុចនេះ ឯកឧត្តម

សុំឱ្យសរសេរក្នុងកំណត់ហេតុដើម្បីឱ្យខាងថ្នាក់លើ និងស្ថាប័នកំពូលបានដឹងផងថា នេះជាការកើតទុកមិនសុខចិត្តលើអ្វីមួយដែលគួរគប្បីពិចារណា។ យើងនៅសល់ពេលតែ២ឆ្នាំទៀតទេដល់ថ្ងៃបោះឆ្នោត ចុះហេតុអ្វីមិនយកច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់បោះឆ្នោតឃុំ-សង្កាត់មកមើលឡើងវិញនូវចំណុចវិជ្ជមាន និងអវិជ្ជមាន។ ឯកឧត្តមថ្លែងថា គំរោងរៀបចំធ្វើសេចក្តីព្រាងច្បាប់វិសោធនកម្មគួរសុំអង្គការផ្សេងៗឱ្យលោកបានជួយមើល និងផ្តល់ជាអនុសាសន៍ រួចឆ្លងក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី រួចឆ្លងអន្តរក្រសួង ហើយឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី រួចបានបញ្ជូនទៅសភា។ ច្បាប់ខ្លះបានអនុញ្ញាតឱ្យធ្វើសេចក្តីស្នើច្បាប់ ប៉ុន្តែច្បាប់អញ្ចឹងៗពីដើមមកទំលាប់ធ្វើឆ្លងកាត់ក្រសួងជាដំរាប តែឯកឧត្តមមានការស្រងាកចិត្តដែលអាយុកាន់តែចាស់ ហើយធ្វើគណបក្សនយោបាយជិត៤០ឆ្នាំមកហើយមើលអត់ឃើញកោះត្រើយអ្វីសោះ។ តែទោះជាយ៉ាងនេះក្តី ចេះតែទ្រាំតស៊ូទៅដើម្បីប្រយោជន៍របស់ជាតិ ព្រោះចង់ឃើញពហុបក្សដែលនៅក្នុងរដ្ឋធម្មនុញ្ញចែងថា ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រមានព្រះមហាក្សត្រសោយរាជ្យ តែលោកមិនកាន់អំណាច គឺរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ យើងពេញចិត្តទាំងអស់គ្នា ប៉ុន្តែមានពហុបក្សៗធ្វើមិនស្រួលគឺអាចនៅសល់តែមួយបក្សប៉ុណ្ណោះក៏ថាបាន។

លោក **ឱក សេរី សោភក្តិ៍** បានជំរាបអង្គប្រជុំថា ខាងលេខាធិការដ្ឋានខប់សែល ទើបបានទទួលចំណារឯកភាពរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃអនុញ្ញាតឱ្យវិទ្យាស្ថានចុះធ្វើការវាយតម្លៃ និងរៀបចំកិច្ចប្រជុំ ខប់សែលប្រ៉ែម ថ្នាក់ខេត្ត-ក្រុង នៅខែតុលា និងវិច្ឆិកា សំរាប់៤ខេត្ត-ក្រុងខាងមុខនេះ។ នេះបង្ហាញឱ្យឃើញនូវការគាំទ្ររបស់ក្រសួងមហាផ្ទៃ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាដែរក្នុងយន្តការខប់សែលយើងនេះ។

លោក **គិត ទូច** មន្ត្រីកម្មវិធីនៃមជ្ឍមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ បានបង្ហាញនូវការកត់សំគាល់របស់លោកលើការលើកឡើងរបស់វៀមច្បងមុនៗ។ វៀមច្បងខាង គជប កត់សំគាល់ថា គជប លោកឈរលើស្មារតីទទួលខុសត្រូវជាប្រវត្តិសាស្ត្រ ហើយវៀមច្បងខាង និកហ្វិច គាត់សំគាល់លើសុភាសិតបុរាណខ្មែរ ថា "ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី " នេះលោកចង់ផ្តោតទៅលើស្មាដៃយុត្តិធម៌ សីលធម៌សាកលពាក់ព័ន្ធនឹងយុត្តិធម៌ មានន័យថា សូមឱ្យស្មារតីនៃការគិតគូរ ការប្រជែងយកឈ្នះចាញ់ដើម្បីបានការគាំទ្រពីប្រជាពលរដ្ឋនេះធ្វើដោយយុត្តិធម៌ ធ្វើដោយភាពត្រឹមត្រូវ ហើយចំមុខជាជាងដែលធ្វើឱ្យខកការរំពឹង។ ចំណុចនេះវាភ្ជាប់ទៅនឹងបទអន្តរាគមន៍របស់ឯកឧត្តមអគ្គលេខាធិការរង គជប គឺថានៅខកចិត្តដែលនៅសង្គមស៊ីវិលស្រែកពីចំងាយ ហើយមិនចូលជួយការងារ គជប នៅក្នុងក្របខ័ណ្ឌច្បាប់ ក៏ដូចជានៅក្នុងនីតិវិធីផ្សេងៗ។ ហើយមានចំណុចខ្លះធ្វើឱ្យ គជប នេះចេញជាសេចក្តីសំរេចជាសវនាការក្តី ឬសេចក្តីសំរេចក្តីដទៃទៀតមិនបានការគាំទ្រពីអាជ្ញាធរពាក់ព័ន្ធដទៃទៀត ជាពិសេសអាជ្ញាធរដែលពាក់ព័ន្ធនឹងអំណាចតុលាការ។ នេះគឺជាចំណុចមួយដល់ពេលយើងមើលមិនគ្រប់ជ្រុងទៅ ជំហានទីមួយយើងបន្ទោស គជប ប៉ុន្តែបើយើងមើលជ្រុងម្ខាងទៀត យើងត្រូវបន្ទោសតុលាការមិនសហការជាមួយ គជប ឬក៏ស្ថាប័នដទៃទៀត។ លោកបានលើកឡើងយ៉ាងច្រើនអំពីបញ្ហាទំនាស់ប្រព័ន្ធច្បាប់ដែលនិយាយអំពីបទល្មើសឥតពាក់ព័ន្ធនឹងការបោះឆ្នោត ឬប្រើប្រាស់សិទ្ធិស៊ីវិល សិទ្ធិនយោបាយក្នុងការបោះឆ្នោត គឺក្រមព្រហ្មទណ្ឌសង្គមចាស់កំណត់បានច្បាស់ណាស់ថា ជាបទល្មើសព្រហ្មទណ្ឌ ហើយការដាក់ទោសពិន័យជាប្រាក់គឺជាទោសទ័ណ្ឌ អញ្ចឹងទោសទ័ណ្ឌ គឺជាទោសអាជ្ញា អញ្ចឹងបើសិន គជប ជាអង្គការប្រតិបត្តិមិនមែនអំណាចតុលាការ ហើយដែលដើរទៅតាមយន្តការនៃអំណាចតុលាការគឺខុសច្បាប់ខុសប្រព័ន្ធច្បាប់តែម្តង អញ្ចឹងហើយមិនអាចអនុវត្តបានទេ។ កាលពីបោះឆ្នោតឃុំ-សង្កាត់ លោកធ្លាប់បានគូសបញ្ជាក់អំពីរឿងនេះថា ការប្រើប្រាស់អំណាចពាក់ព័ន្ធនឹងអំណាចតុលាការ សូមឱ្យប្រយ័ត្ន ហើយ

មកដល់ឆ្នាំ២០០៣ គជប បានកាត់ក្តីករណី៣ ហើយដែលករណី៣នេះ គឺអ្នកដែលរងក្តីគាត់ក៏បានសួរយោបល់ពីរឿងនេះ ព្រោះវាពាក់ព័ន្ធនឹងប្រព័ន្ធច្បាប់សុទ្ធសាធ។ នៅក្នុងការប្រជុំខប់សែលលើកក្រោយទៀត លោកសូមឱ្យដាក់ជាប្រធានបទមួយនៅក្នុងរបៀបវារៈដើម្បីជជែកគ្នាពាក់ព័ន្ធនឹងទិដ្ឋភាពខាងសង្គមស៊ីវិល និងការដែលមិនបានផ្តល់ជំហរសម្បទាននៅក្នុងការជួយការងារការបោះឆ្នោតព្រឹទ្ធសភានៅក្នុងដំណាក់កាលនេះ។ ហើយឯកឧត្តម អ៊ុក ភូរិ លោកបានគូសបញ្ជាក់ថា គេធ្វើច្បាប់សំរាប់អ្នកឈ្នះនេះគឺជាផ្នែកមួយនៃសីលធមិសាកលដែលថាច្បាប់ត្រូវធ្វើឡើងឱ្យស្មើមុខ ហើយឱ្យរំពឹងបានទាំងអស់គ្នាថាយន្តការច្បាប់ ក្របខ័ណ្ឌ ច្បាប់ យន្តការស្ថាប័នស្របច្បាប់ដែលរៀបចំដំណើរការទៅមុខនោះធ្វើម៉េចឱ្យមើលឃើញទាំងអស់គ្នា ។ ជាពិសេសគោលការណ៍បោះឆ្នោតអសាកល ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ គឺជាការអំពល់មួយដែលពិបាកយល់គោលការណ៍បោះឆ្នោតអសាកល គឺអ្នកឯកទេសច្បាប់ជាច្រើនមិនយល់ ហើយចុងក្រោយគឺយើងបានរៀបចំច្បាប់បោះឆ្នោតព្រឹទ្ធសភាមួយដែលមានន័យស្មើនឹងគោលការណ៍បោះឆ្នោតសាកលមិនចំពោះ។ ប៉ុន្តែយើងមិនបានបោះឆ្នោតសាកលដោយសារតែយើងមានតែក្រុមប្រឹក្សាឃុំ-សង្កាត់ និងសមាជិកសភាតំណាងរាស្ត្រ។ អញ្ចឹងគឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់តាមប្រព័ន្ធដែលមាននិយមនៅប្រទេសបារាំង ប្រព័ន្ធដែលមាននិយមនៅប្រទេសអាមេរិកទេ ដូច្នេះនេះជាក្របខ័ណ្ឌច្បាប់ធម្មនុញ្ញមួយដែលមានលក្ខណៈប្រឡាយកាត់ ។

ហើយជាចុងក្រោយលោកបានធ្វើចំណាប់អារម្មណ៍ជូសតំណាងគណបក្ស សម រង្ស៊ី អំពីភាពអយុត្តិធមិមួយដែលគ្មានច្រកចេញដោយសារកាលនោះគេបានកាត់ក្តី គេបានដោះស្រាយបញ្ហាបណ្តឹងប្រហែលជា ៩២ ឬ ៩៤បណ្តឹងរបស់គណបក្ស សម រង្ស៊ី នៅឆ្នាំ ២០០៣ ដោយច្រានចោលបណ្តឹងទាំងនោះ ហើយពេលដែលគណបក្ស សម រង្ស៊ី រុញបណ្តឹងមកដល់ គជប ក្រុមប្រឹក្សាធម្មនុញ្ញប្រកែកថា មិនមែនជាសមត្ថកិច្ចខ្លួន ហើយបិទផ្លូវតវ៉ា នេះមានន័យថាយ៉ាងម៉េច មានន័យថា មនុស្សគិតថាខ្លួនរងអយុត្តិធមិទៅដល់កន្លែងស្វែងរកយុត្តិធមិកំពូល គេប្រាប់ថា អ្នកឯងមិនបាច់មករកយុត្តិធមិទេ ហើយអ្នកឯងមិនបាច់តវ៉ាទៅកន្លែងណាទៀតទេ។ ត្រង់នេះវាពាក់ព័ន្ធនឹងប្រព័ន្ធច្បាប់ដែលថាតើក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកមើលភាពទំនាស់គ្នានៃអំណាចតុលាការហ្នឹង និងអំណាចអាជ្ញាធរប្រតិបត្តិហ្នឹងយ៉ាងម៉េចដែរ។ ត្រង់ហ្នឹងហើយបើសិនជាក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកបកស្រាយច្បាប់ ហើយមិនស្រាយចំណងនេះទេតើឱ្យអ្នកណាស្រាយ ព្រោះគណបក្សនយោបាយក៏ដូចជាសកម្មជនដទៃទៀតដែលមិនអាចយល់ពីគំនិតប្រព័ន្ធច្បាប់បានច្បាស់លាស់ទាំងអស់គ្នា។ លោកគិតថា សូម្បីតែក្នុងជួរថ្នាក់ដឹងនាំគណបក្ស សម រង្ស៊ី ក៏មានអ្នកច្បាប់ អ្នកឯកទេសច្បាប់មួយចំនួនដែរ ប៉ុន្តែការយល់ដឹងក៏មានការកំណត់ដែរ។ មានបទពិសោធន៍មួយនៅតុលាការខេត្តកំពង់ចាម គឺគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ខេត្តបានសហការគ្នាជាមួយនិងព្រះរាជអាជ្ញា ប៉ុន្តែយើងអត់មានបទបញ្ជា នីតិវិធីនិយាយច្បាស់អំពីក្របខ័ណ្ឌការសហការ និងបញ្ជូនកូនក្តីឡើងសវនាការយ៉ាងម៉េច។

លោក **ឱក សេរី សោភ័ក្តិ** បានឯកភាពនូវការលើកឡើងអំពីក្របខ័ណ្ឌច្បាប់របស់លោក **គិត ទូច** និងស្នើសុំឱ្យអង្គប្រជុំ ជាពិសេសស្ថាប័នណាដែលមានសមត្ថកិច្ច មេត្តាពិនិត្យក្របខ័ណ្ឌច្បាប់ទាក់ទងទៅនឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងការបោះឆ្នោតថ្នាក់ជាតិ។ ព្រោះទោះបីជាជជែកគ្នាជាមួយ គជប ក៏ដោយ ក៏នៅតែមានការខ្វះចន្លោះខ្លះ ហើយសូម្បីតែ គជប ក៏មានការបារម្ភដែរ ដែលត្រូវធ្វើវិសោធនកម្មច្បាប់បោះឆ្នោះនេះឡើងវិញទាក់ទងនឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់និងការបោះឆ្នោតថ្នាក់ជាតិនៅឆ្នាំ២០០៧-២០០៨ ។ លោកបានស្នើទៅខាងមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ ដែលមានជំនាញនៅក្នុងកិច្ចការច្បាប់ ហើយមានភាពជាអព្យាក្រឹត សូមមេត្តាពិនិត្យក្របខ័ណ្ឌច្បាប់ទាក់ទងនឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងការបោះឆ្នោត

ថ្នាក់ជាតិ តើមានជំពូក និងមាត្រាណាខ្លះដែលយើងគួរតែលើកយកមកពិចារណានៅក្នុងក្របខ័ណ្ឌរបស់ខប់សែល ដើម្បីចែកជូនអង្គប្រជុំឱ្យបានជ្រាប ។ លោកក៏បានសំណូមពរដល់សមាជិកផ្សេងៗទៀតមេត្តាជួយពិនិត្យច្បាប់នេះទាំងអស់ឡើងវិញផងដែរ ហើយយើងយកចំណុចណាមួយដើម្បីដាក់ចូលក្នុងរបៀបវារៈរបស់ខប់សែលខមក្តិ ខប់សែលឡឹមក្តិ ដើម្បីជជែកឱ្យទាន់ពេលវេលាជៀសវាងការនិយាយថាគ្មានពេលគ្រប់គ្រាន់ ។

លោក **សន ចាន់ថៃ** អគ្គលេខាធិការរងនៃគណបក្សរណសិរ្សជនជាតិខ្មែរបានលើកឡើងនូវចំណាប់អារម្មណ៍ និងអនុសាសន៍មួយចំនួនដូចខាងក្រោម ។

ករណីបំភិតបំភ័យផ្ទាល់ រហូតមានករណីលេចចេញបញ្ហារាត្រីឆ្កែព្រុះទៀតផង និងការគំរាមកំហែង នេះគឺជាបញ្ហាធំបំផុតដែលគ្មានអ្នកបោះឆ្នោតណាដែលលោកសុខចិត្តទៅបោះដោយមានការគំរាមកំហែងនៅពីក្រោយដោយសំងាត់នោះទេ ។ ដូច្នេះ គជប គួរពិនិត្យ និងដោះស្រាយផង ។ លោកបានឯកភាពលើចំណុចមួយរបស់ឯកឧត្តមអគ្គលេខាធិការរង គជប ដែលបានលើកឡើងថា វានៅមានឥទ្ធិពល ដូច្នេះ គជប គួរយល់ហើយ ហើយត្រូវធ្វើការកែទំរង់ឱ្យបានច្រើន ។ រីឯបញ្ហាសមាសភាព គជប គឺមាននិន្នាការនយោបាយគណបក្សលាយឡំ គ្រាន់តែរូបភាពមិនចេញជារូបរាង ដូច្នេះហើយអង្គការសង្គមស៊ីវិលក៏បានលើកឡើងថា គ្រាន់តែឃើញរូបភាពរចនាសម្ព័ន្ធ គឺមានលក្ខណៈលំអៀងរួចទៅហើយ ព្រោះមិនទាន់មានបុគ្គលឯករាជ្យនៅក្នុងនេះ ។ គណបក្សរណសិរ្សជនជាតិខ្មែរតែងប្រកាន់គោលការណ៍គំនិតដូចខាងអង្គការសង្គមស៊ីវិលដែរ គឺគួរតែរៀបចំបុគ្គលដែលមានលក្ខណៈឯករាជ្យសំរាប់កាន់កិច្ចការនេះ ហើយចំណុចមួយទៀតគឺប្រព័ន្ធឃោសនារហូតដល់គណបក្សរណសិរ្សជនជាតិខ្មែរបានដើរចេញពីការបែងចែកម៉ោង ហើយនេះជាទិដ្ឋភាពមួយដោយសារវាមានលក្ខណៈអយុត្តិធមិច្រើនពេក ច្បាប់បង្កើតមកគឺសំរាប់តែអ្នកដែលមានអំណាចខ្លាំង ។ ចំណុចមួយទៀត គឺករណីស្មៀនឃុំដែលភាគច្រើនចេញពីគណបក្សប្រជាជនកម្ពុជា ហើយរូបភាពនេះបានបង្ហាញនូវភាពលំអៀងរួចទៅហើយ ។

លោកសង្កេតឃើញថា ការធ្វើច្បាប់កន្លងមកគឺដើម្បីតំរូវតែខ្លួនឯងអ្នកមានអំណាច ដោយមិនគិតដល់អ្នកទន់ខ្សោយទាល់តែសោះ ។ ឧទាហរណ៍ជាក់ស្តែងដូចជា ព្រឹទ្ធសភាកើតឡើងដើម្បីដោះស្រាយស្ថានភាពជាក់ស្តែង ប៉ុន្តែព្រឹទ្ធសភា បើលក្ខណៈសាមញ្ញនិយាយថា ព្រឹទ្ធសភាបោះឆ្នោតមុនឃុំ-សង្កាត់ ហើយព្រឹទ្ធសភានេះឯង ច្បាប់មិនតំណាងឱ្យទាំងមូលទេគឺ តំណាងឱ្យមិនចំពោះ ។ អញ្ចឹងគណបក្សរណសិរ្សជនជាតិខ្មែរមើលឃើញថា ប្រហែលជាព្រឹទ្ធសភាកើតមុន ហើយការបោះឆ្នោតឃុំ-សង្កាត់កើតក្រោយ មានន័យថា ព្រឹទ្ធសភានេះកើតមុនវិញ អញ្ចឹងវាប្រគាយប្រគប់គ្នា បានន័យថា បើតំណាងវាមិនតំណាងទៅវិញ អញ្ចឹងលក្ខណៈច្បាប់នៅកន្លែងនេះបំរើតែមនុស្សមានអំណាចទេ ។

លោកបានសំណូមពរឱ្យ គជប ត្រូវតែកែទំរង់ឱ្យបានច្រើន ហើយដោះស្រាយបញ្ហាបណ្តឹងតាមគោលការណ៍ច្បាប់ជាធរមានប្រកបដោយយុត្តិធម៌ និងកុំប្រើវិធីសំរបសំរួលច្រើនពេក ។ តាងនាមគណបក្សរណសិរ្សជនជាតិខ្មែរ លោកសូមគាំទ្រកម្មវិធីខប់សែល ហើយសូមអរគុណចំពោះវិទ្យាស្ថាន CDRI ដែលបានរៀបចំវេទិកានេះឡើង ហើយលោកសន្យាថានឹងបន្តចូលរួមក្នុងសកម្មភាពដ៏មានសារៈសំខាន់នេះ ។

លោក **គឹម សុង** នាយកប្រតិបត្តិ អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស បានចាប់អារម្មណ៍លើចំណុចលើកឡើងរបស់ឯកឧត្តមអគ្គលេខាធិការរង គជប អំពីការគណបក្សចាញ់ឆ្នោតមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតរាល់ពេលនៃការបោះឆ្នោត ហើយនេះជាការពិត ហើយបានក្លាយទៅជាប្រពៃណីតាំងពី១៩៩៣ ១៩៩៨ ២០០៣មកម្លេះ ។ បើ គជប ទទួលស្គាល់បែបហ្នឹង គជប

គួរតែរកឱ្យឃើញនូវឫសគល់នៃការមិនទទួលស្គាល់នោះ ហើយព្យាយាមកាត់ឫសនោះចោលកុំឱ្យវានៅសល់ដើម្បីឱ្យមានការទទួលស្គាល់នៅពេលខាងមុខ។ ហើយចំពោះមូលហេតុ ដែលគេបដិសេធមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតនេះ លោកមើលឃើញថា មានមូលហេតុមកពីការបោះឆ្នោតមិនយុត្តិធម៌ មានការគំរាមកំហែង ការបំភិតបំភ័យ រហូតដល់ទៅមានអំពើហិង្សាការសំលាប់នៅពេលបោះឆ្នោតម្តងៗ វិសមភាពខាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ល។ ប៉ុន្តែមូលហេតុសំខាន់បំផុតនោះ ដែលគេមិនទទួលស្គាល់នោះ គឺការលួចបន្លំសន្លឹកឆ្នោតតែម្តង។ លោកបានបន្ថែមថា ចុះបើយើងមើលឃើញថា គេចោទយើងថាមានការលួចបន្លំសន្លឹកឆ្នោត ហើយមិនទទួលស្គាល់សន្លឹកឆ្នោត៣លើករួចមក ហើយហេតុអ្វីបានជា គជប មិនមានវិធានការទប់ស្កាត់ចំណុចនេះកុំឱ្យចោទថាវាបន្លំបាន ។ ចុះបើគេមានភស្តុតាង ថាមានការលួចសន្លឹកឆ្នោតមែន ហើយគេស្នើឱ្យរាប់ឡើងវិញ ឧទាហរណ៍ដូចនៅស្វាយរៀងកន្លងមក មូលហេតុអ្វីបានជា គជប មិនបានរាប់ឡើងវិញ។ វិធានការទប់ស្កាត់កុំឱ្យមានអំពើលួចបន្លំសន្លឹកឆ្នោតនេះម្តេចក៏ គជប មិនចាត់វិធានការឬ នីតិវិធីយ៉ាងណាកុំឱ្យមានការបន្លំបាន ឧទាហរណ៍ថាមានការសង្កេតការណ៍ពីគ្រប់គណបក្សដែលចូលរួមការបោះឆ្នោត ពីអង្គការក្រៅរដ្ឋាភិបាលហើយ ប៉ុន្តែជួនកាលអ្នកសង្កេតការណ៍ទាំងអស់នោះអត់មានជំនាញមួយពិតប្រាកដ។ ដូចនេះ គជប គួរតែប្រមូលអ្នកដែលចុះឈ្មោះសង្កេតការណ៍ទាំងអស់នោះមកធ្វើការអប់រំពីជំនាញ។ លោកគិតថា ជាចំណុចមួយល្អគឺថាមិនទុកឱ្យអង្គការនីមួយៗអប់រំបុគ្គលិករបស់ខ្លួនដោយខ្លួនឯងទេ ជួនកាលអង្គការនីមួយៗអត់មានជំនាញដោយខ្លួនឯងផង ហើយទៅអប់រំបុគ្គលិកខ្លួនឯងមិនច្បាស់ ហើយរើសបុគ្គលិកសំរាប់ទៅសង្កេតការណ៍ បុគ្គលិកនោះក៏មិនច្បាស់ និងគ្មានសមត្ថភាពធ្វើឱ្យតែបានលំៗយកតែលុយ ។

ទាក់ទងនឹងការផ្សព្វផ្សាយលទ្ធផលបោះឆ្នោតមុន គជប ប្រកាសលទ្ធផល លោកនៅចាំបានថា នៅសណ្ឋាគារភ្នំពេញពេលដែលលោកបានចូលរួមសន្និសីទចាប់ផ្តើមយន្តការខប់សែល លោកបានសួរទៅឯកឧត្តមប្រធាន **អ៊ឹម សួស្តី** ថា ឯកឧត្តមទទួលស្គាល់ទេថាមានការប្រកាសលទ្ធផលនៃការបោះឆ្នោតមុន គជប ចេញ គាត់បានឆ្លើយមកវិញថា គាត់ទទួលស្គាល់។ ប៉ុន្តែលោកនៅចាំបានមួយពាក្យទៀតគាត់ថា គេមានទូរស័ព្ទរបស់គេ ហើយគេទាក់ទងគ្នាតាមទូរស័ព្ទ ហើយគេប្រកាសមុន ដូច្នេះគាត់មិនដឹងធ្វើយ៉ាងណា។ លោកយល់ថា បើបញ្ហាកើតឡើង គជប អត់មានវិធានការដោះស្រាយ វាធ្វើឱ្យប្រជាជនវង្វេងវង្វាន់។ ដូច្នេះលោកសំណូមពរឱ្យមានការគ្រប់គ្រងត្រឹមត្រូវដោយដាក់ទោសបញ្ញត្តិដល់អ្នកដែលប្រព្រឹត្តខុសនីតិវិធី។

លោក **អ៊ី មុយលី** តំណាងគណបក្ស សម រង្ស៊ី បានថ្លែងអំណរគុណវិទ្យាស្ថាន CDRI ដែលបានរៀបចំឱ្យមានយន្តការបង្ការទំនាស់នេះឡើងដើម្បីជួយដំណើរការបោះឆ្នោតនៅកម្ពុជា។ លោកបានសួរតំណាងក្រសួងមហាផ្ទៃដែលមានវត្តមានក្នុងកិច្ចប្រជុំនេះថា មកទល់នឹងពេលនេះ តើតួលេខអត្តសញ្ញាណប័ណ្ណមានចំនួនប៉ុន្មានហើយដែលបានផ្តល់ជូនប្រជាពលរដ្ឋ ហើយហេតុអ្វីបានជាតួលេខនៃចំនួនប្រជាពលរដ្ឋមានភាពខុសគ្នារវាងក្រសួងមហាផ្ទៃ និង គជប។

ទាក់ទងនឹងការរាប់សន្លឹកឆ្នោតដំបូងហើយចុះក្នុងទំរង់១១០៣ ហើយបានចម្លងបន្តទៅដល់ ១១០៥ ត្រង់ចំណុចនេះ លោកឆ្ងល់ថាហេតុអ្វី ក៏ចាំបាច់ចម្លងពីមួយទៅមួយនាំឱ្យមានបញ្ហា បើថាអត់មានកុំព្យូទ័រសំរាប់ព្រីនភ្លាមៗចែកគ្នា ក៏យើងអាចប្រើក្រដាសផ្តិតសរសេរមួយដានដល់ទៅ ២-៣ ហើយអាចឱ្យតំណាងគណបក្សចុះហត្ថលេខាទៅស្រេចទៅហើយ។ ក៏ប៉ុន្តែមានបញ្ហាធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺនៅលើទំរង់នោះមានសុទ្ធតែស្នាមទឹកលុប ហើយចំណុចនេះ យើងគួរខ្មាស់ប្រជាពលរដ្ឋខ្មែរ ដែលលោកខំបោះឆ្នោតឱ្យរឿងអីដែលយើងយកលទ្ធផលបោះឆ្នោតដែលជាបញ្ហាជាតិមួយទាំងមូលមកលុបស្រេចតែចិត្តយើង។ ត្រង់ហ្នឹងហើយ ជា

លទ្ធផលដែលឯកឧត្តមអគ្គលេខាធិការ គជប ទេព នីថា ធ្លាប់បានមានប្រសាសន៍ថា គ្មានគោលការណ៍ណាដែលមិនឱ្យគាត់លុបទេ។ ពាក្យបណ្តឹងដែលខាងលោកបានដាក់ទៅភាគច្រើនតែងតែត្រូវបានទាត់ចោលដោយ គជប ទោះបីជាមានភស្តុតាងបញ្ជាក់ក៏ដោយ ។ លោកបានលើកករណីឃុំមួយនៅខេត្តព្រៃវែង លោកបានប្តឹងពីបុគ្គលម្នាក់ថាជាជនជាតិយួន ហើយមេឃុំគាត់ក៏បានចារច្បាស់ណាស់ថា បុគ្គលនោះពិតជាជនជាតិយួនមែន ប៉ុន្តែគាត់មិនហ៊ានដោះស្រាយទេ តែខាងលោកដាក់ពាក្យបណ្តឹងនោះមក គជប ឯកឧត្តមអគ្គលេខា គជប ថាបណ្តឹងរបស់លោកគ្មានលក្ខខណ្ឌគ្រប់គ្រាន់ទេ គាត់ចារវៃត្រាបដិសេធភ្លាម។ បើខាងលោកបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ក៏គេអត់ទទួលដោះស្រាយដែរទាល់តែមានការប្រជុំដោយសមាជិក គជប ទាំង៥រូបសំរេចធ្វើបណ្តឹងនោះឱ្យក្លាយទៅជាផ្លូវច្បាប់សិនទើបក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកទៅដោះស្រាយបាន។ ដូច្នេះនេះមិនមែនជាការទទួលជោគជ័យតាមផ្លូវច្បាប់ដូចការលើកឡើងរបស់ឯកឧត្តមអគ្គលេខាធិការរង គជប នោះទេ។ លោកបានសំណូមពរយ៉ាងទទូចឱ្យបញ្ឈប់ការប្រើទឹកលប់លើទំរង់រាប់សន្លឹកឆ្នោតតទៅទៀត ព្រោះថាតំណាងគណបក្សបានចុះហត្ថលេខាលើទំរង់នោះមែន ប៉ុន្តែលទ្ធផលដែលលុបតើយើងអាចទទួលយកបានដែរឬទេ ?

លោក **អ៊ឹម សហវុឌ្ឍី** តំណាងមកពីគណបក្ស ហ្វ៊ុនស៊ិនប៉ិច បានថ្លែងទាក់ទងនឹងច្បាប់បោះឆ្នោតព្រឹទ្ធសភា ដែលមានមតិជាច្រើនបានលើកឡើងថា ច្បាប់បោះឆ្នោត គឺធ្វើសំរាប់តែអ្នកមានអំណាច ឬសំរាប់តែគណបក្សមានអំណាច ដូច្នេះលោកសូមផ្តល់ជាយោបល់ថា ច្បាប់នេះគឺមុននឹងយកមកប្រើបាន គឺត្រូវបានអនុម័តដោយសភា និងត្រូវបានឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រ ហើយច្បាប់នេះមិនសំរាប់បុគ្គលណាមួយ ឬសំរាប់គណបក្សណាមួយទេ គឺសំរាប់ទូទៅ។ ចំពោះប្រទេសដែលគេមានឧស្សាហកម្មជឿនលឿន ហើយគេប្រកាន់របបលទ្ធិប្រជាធិបតេយ្យ ហើយគេគោរពសិទ្ធិមនុស្ស គោរពសេរីភាព ហើយជាប្រទេសមហាអំណាចទៀត គឺច្បាប់បោះឆ្នោតព្រឹទ្ធសភារបស់គេមានភាពប្រហាក់ប្រហែលនឹងច្បាប់បោះឆ្នោតព្រឹទ្ធសភានៅប្រទេសយើងដែរ។

ចំពោះប្រទេសកម្ពុជាយើង គឺបានយកប្រព័ន្ធច្បាប់តាមបែបបារាំងមកអនុវត្តភាគច្រើន ដូច្នេះតាមច្បាប់នេះគឺប្រហាក់ប្រហែលនឹងច្បាប់នៅស្រុកបារាំងដែរ។ តាមយោបល់របស់លោកច្បាប់បោះឆ្នោតព្រឹទ្ធសភានេះ គឺសមស្របទៅតាមលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជាបច្ចុប្បន្ន ពីព្រោះច្បាប់នេះវាប្រហាក់ប្រហែលនឹងប្រទេសដែលអភិវឌ្ឍន៍ ដូចជានៅប្រទេសបារាំង ប្រទេសមហាអំណាចប្រទេសអាមេរិក អ៊ីតាលី និងអាល្លឺម៉ង់ ។ លោកបានសំណូមពរដល់គណបក្សមួយចំនួនដែលមិនទាន់មានក្រុមប្រឹក្សាឃុំ ឬសមាជិកព្រឹទ្ធសភា រដ្ឋសភា ហើយមិនទាន់បានកាន់អំណាចនៅក្នុងរដ្ឋាភិបាល សូមខំតស៊ូប្រឹងប្រែងឡើងដើម្បីឱ្យបានទទួលអាសនៈ នៅក្នុងសភា។ ដូចជាយើងចង់បន្ត ទៅមហាវិទ្យាល័យ ឬមួយថ្នាក់បណ្ឌិត អនុបណ្ឌិត យើងត្រូវរៀនតាំងពីថ្នាក់បឋមសិក្សារហូតដល់ឌីប្លូមសិន ហើយកាលណាយើងចង់រៀនបាក់ឌុប យើងត្រូវរៀនឌីប្លូមសិន ទើបអាចរៀនបាក់ឌុបបាន កាលណាយើងចង់ចូលមហាវិទ្យាល័យ គឺយើងត្រូវមានឌីប្លូម មានបាក់ឌុប ទើបអាចចូលទៅមហាវិទ្យាល័យបាន។ ដូច្នេះបើយើងចង់បានឱ្យសំលេងបក្សយើងច្រើននៅក្នុងព្រឹទ្ធសភា គឺយើងខំតាំងពីក្រុមប្រឹក្សាឃុំ ខំតាំងពីបោះឆ្នោតរដ្ឋសភា ហើយយើងនឹងអាចឈានទៅព្រឹទ្ធសភាបាន។

**លោក សិន សំបូរ** តំណាងអគ្គលេខាធិការដ្ឋានរដ្ឋសភាបានគូសបញ្ជាក់ថា បញ្ហាតែងតែកើតមានជាបន្តបន្ទាប់ និងបញ្ហាយន្តការនៃការដោះស្រាយតាមប្រព័ន្ធកាត់ក្តី ការដោះស្រាយពី គជប ពីក្រុមប្រឹក្សាធម្មនុញ្ញ អំពីបញ្ហាផ្សេងៗដែលកើតមានឡើងក្នុងដំណើរការបោះឆ្នោត យើងឃើញថា តែងតែមានការដោះស្រាយជាបន្តបន្ទាប់។ លោកសូមលើកទិដ្ឋភាពពីរ ទីមួយ គឺទិដ្ឋភាពផ្លូវច្បាប់ដែលទាក់ទិនទៅនឹងការធ្វើច្បាប់បោះឆ្នោត ធ្វើជាអនុក្រឹត្យ ប្រកាស សារាចរណែនាំផ្សេងៗ គេហៅថា លិខិតបទដ្ឋាន

ក្រោមច្បាប់ដើម្បីណែនាំការអនុវត្តន៏ច្បាប់ឱ្យមានប្រសិទ្ធភាព និងអាចធ្វើបាន។ ក្នុងនោះយើងឃើញថាច្បាប់បោះឆ្នោតព្រឹទ្ធសភារបស់យើងបានកើតចេញមកហើយ ហើយក្នុងហ្នឹង ក៏ គជប លោករៀបចំជាបទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភានៅអាណត្តិទីពីរ នេះក៏ឃើញបានរួចមកហើយដែរ គឺសំរាប់ណែនាំការអនុវត្តន៏ច្បាប់ ពីព្រោះច្បាប់គឺលោកមិនអាចចែងលំអិតពីកិរិតផ្សេងៗ បញ្ហាតូចៗបានទេ ពីព្រោះថា ទីមួយគឺធ្វើឡើងដោយស្ថាប័ននីតិបញ្ញត្តិ ដែលលោកមិនអាចនឹងយល់បានស៊ីជំរៅគឺទៅដល់បញ្ហាតូចៗបានទេ។ ដូច្នេះសួរថាតើអ្នកណាដែលយល់អំពីបញ្ហានេះ គឺមានតែអ្នកអនុវត្តន៏ផ្ទាល់ទេ គឺ គជប ដែលដឹងអំពីបញ្ហាដែលកើតឡើងនៅមុន និងក្រោយការបោះឆ្នោត អញ្ជឹងទេលោករៀបចំជានីតិវិធី ជាបទបញ្ជាផ្សេងៗ ដើម្បីណែនាំការអនុវត្តន៏ដោយពឹងផ្អែកឱ្យស្របទៅនឹងច្បាប់បោះឆ្នោតដែលជាគោល ដែលជាវិធានមួយសំរាប់ឱ្យអនុវត្ត។ ដូច្នេះយើងឃើញថា កន្លងមកមានបញ្ហាដែលកើតឡើងជាច្រើនដែលពាក់ព័ន្ធនឹងអំណាចនៃការបញ្ជារហូតដល់ថ្នាក់ផាកពិន័យទៀត នោះហើយមកពីអ្នកនោះមិនបានគោរពទៅតាមនីតិវិធី និងបទបញ្ជាដែលជាការណែនាំការអនុវត្តន៏ច្បាប់។ សំណូមពររបស់លោកគឺថា ដើម្បីជៀសវាងការបង្កើតឱ្យមានបញ្ហាដដែលៗទៀត ត្រូវដាក់ទោសដល់អ្នកដែលមិនរាងចាលចំពោះការអនុវត្តន៏ មិនថាគណបក្សណាទេ គឺយើងនិយាយក្នុងន័យតម្លាភាព ក្នុងន័យភាពស្មើគ្នាចំពោះមុខច្បាប់ បើសិនយើងហាមឃាត់អ្នកណា គណបក្សណាមួយ អ្នកណាមួយដែលមិនឱ្យចូលទៅកន្លែងណាមួយ អ្នកណាក៏មិនបានដូចគ្នាដែរ ពីព្រោះនេះជាគោលការណ៏ច្បាប់ គឺគោលការណ៏ស្មើភាពគ្នានៅចំពោះមុខច្បាប់មិនអាចអ្នកធ្វើបាន អ្នកណាផ្សេងទៀតធ្វើមិនបានទេ។ បើសិនជានីតិវិធីផ្សេងៗ បទបញ្ជាផ្សេងៗដែលនៅខ្វះចន្លោះ ជាពិសេសទាក់ទងនឹងបញ្ហាដែលយើងកំពុងលើក កន្លងមកនេះ គឺយើងត្រូវលើកយកមកសិក្សាដើម្បីឱ្យដឹងថាតើបញ្ហានេះមានចែងហើយឬនៅនៅក្នុងបទបញ្ជា និងនីតិវីធី បើមិនទាន់មានចែងទេ យើងគួរតែសិក្សា បើសិនជាកើតឡើង តើយើងគួរមានវិធានការណាដែរដើម្បីដោះស្រាយ តើស្ថាប័នណា អ្នកណាដែលជាយន្តការសំរាប់ការដោះស្រាយនៅក្នុងករណីដោះស្រាយមិនបាន តើយើងមានអ្វីសំរាប់ដោះស្រាយជាបន្តទៀត។ ជាក់ស្តែងក្នុងការដោះស្រាយទំនាស់ការបោះឆ្នោត គឺមានតែក្រុមប្រឹក្សាធម្មនុញ្ញទេ ដែលជាស្ថាប័នកំពូលមួយក្នុងការដោះស្រាយវិវាទដែលកើតឡើងអំពីការបោះឆ្នោត ហើយបិទផ្លូវតវ៉ាទៀត ដូច្នេះយើងត្រូវមើលឱ្យលំអិតពីព្រោះយើងឃើញថា បទបញ្ជា និងនីតិវីធី គឺកើតឡើងដោយសារ គជប ជាអ្នករៀបចំ អញ្ជឹង គជប អាចធ្វើវិសោធនកម្មលឿនណាស់មួយថ្ងៃក៏គាត់អាចកែបានដែរ បើក្នុងករណីដែលមានទឡ្ហីករណ៏ច្បាស់លាស់ ហើយតំរូវការចាំបាច់ត្រូវតែកែ។ ដូចនេះច្បាប់គឺទុកឱកាសអញ្ជឹង គឺទុកឱ្យណែនាំការអនុវត្តន៏ នេះជាលក្ខណៈមួយបើកចំហក្នុងផ្លូវច្បាប់ ដើម្បីងាយក្នុងការបត់បែនទៅតាម ការជាក់ស្តែងសរុបទៅ ច្បាប់គឺមិនអាចចែងលំអិតទេ គឺទុកឱ្យលិខិតបទដ្ឋានខាងច្បាប់ដើម្បីណែនាំការអនុវត្តន៏ច្បាប់ ។

ហើយពាក់ព័ន្ធទៅនឹងចំណុចទី២ គឺទិដ្ឋភាពនៃបញ្ហាទូទៅ យើងដឹងហើយថា ការបោះឆ្នោតកើតឡើងពីអ្នកបោះឆ្នោតចូលរួមបោះឆ្នោត ហើយនិងសំរេចលទ្ធផលចុងក្រោយ ដូច្នេះមុននឹងដល់ដំណាក់កាលសំរេចលទ្ធផល គឺមានការបោះឆ្នោតប្រកបទៅដោយយុត្តិធមិ តម្លាភាព ដោយស្របទៅតាមច្បាប់ នីតិវិធីត្រឹមត្រូវ និងដោះស្រាយទំនាស់ទៅតាមនីតិវិធីផ្លូវច្បាប់ត្រឹមត្រូវ តែមុននឹងដល់ដំណាក់កាលបោះឆ្នោត យើងឆ្លងកាត់ពីអ្នកបោះឆ្នោត អញ្ជឹងអ្នកបោះឆ្នោតកំរិតណា ប្រភេទណាដែលអាចបោះឆ្នោតបាន តើមានអ្វីសំរាប់សំគាល់។ ដើម្បីធ្វើអត្តសញ្ញាណប័ណ្ណសំរាប់ការបោះឆ្នោត គឺត្រូវឆ្លងកាត់ ការវាយតំលៃមួយថា អ្នកនេះមានសិទ្ធិបោះឆ្នោតឬទេតាមផ្លូវច្បាប់ដើម្បីឆ្លងដំណាក់កាលវាយតំលៃថា បុគ្គលអាចទទួលប័ណ្ណបោះឆ្នោតបាន មានសិទ្ធិបោះឆ្នោតបាន វាឆ្លងកាត់ដំណាក់កាលនៃងារការផ្លូវច្បាប់។ ច្បាប់យើងមានចែងស្រាប់ អញ្ជឹងទេបញ្ហាពាក់ព័ន្ធនឹងអត្តសញ្ញាណប័ណ្ណនេះ គឺពាក់ព័ន្ធទៅដល់ក្រសួង

មហាផ្ទៃទៀត ដែលលោកមានសមត្ថកិច្ចក្នុងការរៀបចំ និងធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ។ អញ្ចឹងគឺលោកដឹងអំពីច្បាប់ហើយច្បាប់ដែលមុននឹងផ្តល់អត្តសញ្ញាណប័ណ្ណឱ្យជនណាមួយ តើវាឆ្លងកាត់ដំណាក់កាលស្អីខ្លះ ឯកសារណាខ្លះដែលសំអាងបង្ហាញថាអ្នកនេះអាចទទួលបានអត្តសញ្ញាណប័ណ្ណ ហើយឯកសារហ្នឹងមិនមែនបោះចោលទេ ឯកសារនេះត្រូវតែមានតម្កល់ទុកដើម្បីឱ្យដឹងថាគេឱ្យអត្តសញ្ញាណប័ណ្ណអ្នកនេះមួយ គឺគេសំអាងលើឯកសារនេះដែលបង្ហាញថា អ្នកហ្នឹងបានប្រយោជន៏មែន។ ដូចនេះក្រសួងមហាផ្ទៃ លោកអត់មានទោសទេ នេះគឺជានីតិវិធីលំអិតរបស់ក្រសួងមហាផ្ទៃទៀត ដែលយល់ថា កន្លងមកមានអភិបាលខេត្ត-ក្រុងគឺលោកជាអ្នកមានសិទ្ធិសំរេច ហើយទាក់ទងនឹងបញ្ហានេះ លោកគ្រាន់តែសំណូមពរទេថា វាមិនមែនស្រួលទេ ក្នុងគ្រួសារមួយម៉េចយើងមានការលំបាក ចុះទំរាំខេត្ត ទំរាំប្រទេសមួយទាំងមូល ដែលយើងឃើញថាប្រជាពលរដ្ឋមានរហូតដល់៦-៧លាននាក់នោះ។

មួយទៀតពាក់ព័ន្ធទៅនឹងតួលេខខុសគ្នាអំពីចំនួនប្រជាពលរដ្ឋ លោកសំណូមពរឱ្យ គជប និងក្រសួងមហាផ្ទៃគួរតែសហការគ្នាធ្វើយ៉ាងម៉េចដើម្បីពិនិត្យមើលទៅតាមបញ្ហា ធ្វើយ៉ាងម៉េចឱ្យតួលេខដូចគ្នាដើម្បីជៀសវាងការចោទប្រកាន់ថា គជប យកផ្សេងទៅធ្វើបានប៉ុណ្ណេះ ស្រាប់តែក្រសួងមហាផ្ទៃធ្វើប៉ុណ្ណោះ ចំនួនវាខុសគ្នាយ៉ាងម៉េចៗ។

បញ្ហាមួយទៀតពាក់ព័ន្ធនឹងការឃោសនានៅតាមប្រព័ន្ធផ្សព្វផ្សាយ គួរតែយើងមានបទពិសោធន៏ច្រើនហើយ ជាពិសេសជំនាន់អ៊ុនតាក់ដែលលោករៀបចំមានការពេញចិត្តពេញថ្លើមពីប្រជាជនច្រើនណាស់។

ឯកឧត្តម **កែ ប៊ុន ខៀង** តំណាងគណបក្សប្រជាជនកម្ពុជាបានបញ្ចេញនូវចំណាប់អារម្មណ៏ដូចខាងក្រោមៈ
យើងដឹងហើយថាប្រទេសកម្ពុជាយើងទទួលយករបបប្រជាធិបតេយ្យសេរីពហុបក្សដែលចាប់ដំណើរការដំបូងបំផុតនៅឆ្នាំ១៩៩៣ដែលការបោះឆ្នោតនាពេលនោះបានគ្រប់គ្រងដោយអ៊ុនតាក់។ ហើយជាបន្តបន្ទាប់មកកម្ពុជាខ្លួនឯងគឺជាអ្នករៀបចំដំណើរការបោះឆ្នោតហើយដូចជារបាយការណ៏ខាងដើមរបស់លោកនាយកប្រតិបត្តិរបស់ CDRI បានបញ្ជាក់ហើយគឺថា ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ គឺយើងបានធ្វើឱ្យកាន់តែសុក្រឹតនូវដំណើរការបោះឆ្នោត ដែលជាគោលការណ៏គ្រឹះនៃដំណើរការប្រជាធិបតេយ្យ។ ជាការពិតឯកឧត្តមយល់ថា ដំណើរការនេះ វាមិនអាចសុក្រឹត ហើយធ្វើឱ្យពេញចិត្តគ្រប់មនុស្សទាំងអស់ដែលប្រកួតប្រជែងទេ ។ ប៉ុន្តែអ្វីដែលជាសារៈសំខាន់នោះ គឺការធ្វើឱ្យមានយុត្តិធមិកាន់តែច្រើនឡើងទៀត ហើយយើងមិនអាចរកយុត្តិធមិ១00ភាគរយនោះទេ។ ប៉ុន្តែធ្វើយ៉ាងម៉េចឱ្យយុត្តិធមិនោះកាន់តែត្រូវបានពង្រីកថែមទៀត ហើយដូចជាការវាយតំលៃរបស់ CDRI បានបញ្ជាក់ហើយថាពីដំណើរការបោះឆ្នោតមួយទៅដំណើរការបោះឆ្នោតមួយកាន់តែសុក្រឹត ហើយយើងត្រូវយល់ថា ក្នុងរយៈពេលពាអាណត្តិនេះយើងមិនអាចទៅធ្វើច្បាប់ឱ្យសុក្រឹតប្រៀបធៀបទៅប្រទេសនេះប្រទេសនោះបានទេ។ ឯកឧត្តមបានបញ្ជាក់ថាសូម្បីតែនៅសហរដ្ឋអាមេរិកមកដល់ពេលនេះ ក៏នៅតែមានបញ្ហាបោះឆ្នោត ដូចជាបោះឆ្នោតកន្លងមកគណបក្សប្រជាធិបតេយ្យបានចោទគណបក្សសាធារណៈរដ្ឋថានៅរដ្ឋខ្លះគណបក្សសាធារណៈរដ្ឋបានរារាំងប្រជាជនស្បែកខ្មៅ ដែលគាំទ្រគណបក្សប្រជាធិបតយ្យមិនឱ្យបានទៅបោះឆ្នោត។

អ្វីដែលឯកឧត្តមលើកឡើងនេះ គឺមិនមែនជាទឡ្ហីករណ៏សំរាប់ថា ប៉ុណ្ណឹងគ្រប់គ្រាន់ទេ ការពិតប៉ុណ្ណឹងមិនទាន់គ្រប់គ្រាន់ទេ។ ហេតុនេះហើយ បានជាយន្តការខប់សែលគាត់បានរៀបចំដើម្បីធ្វើយ៉ាងម៉េចឱ្យយើងផ្តល់អនុសាសន៏ធ្វើឱ្យដំណើរការបោះឆ្នោតកាន់តែល្អប្រសើរ ។ ឯកឧត្តមនៅចាំថា ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ សុទ្ធតែមានអនុសាសន៏ ហើយរដ្ឋសភាជាតិសុទ្ធតែយកទៅធ្វើការកែសំរួល ជាក់ស្តែងដូចជារឿងសមាសភាព គជប មុនដំបូងត្រូវដាក់តំណាងខាងគណបក្សនយោបាយ ក្រោយ

មកថា ដាក់តំណាងគណបក្សនយោបាយមិនបានទេ ត្រូវដាក់ឥស្សរជន តែរហូតមកដល់ពេលនេះគឺថា គជប នៅតែមានបញ្ហា ហើយឯកឧត្តមយល់ថា ការគ្រប់គ្រងយន្តការមានមនុស្សរាប់ម៉ឺន រាប់សែននាក់មិនមែនជាការងាយស្រួលទេ គឺថាវាងាយនឹងមានបញ្ហា។ យើងត្រូវតែមានមោទនភាពចំពោះការណ៍ដែលប្រជាជនកម្ពុជាយើងរៀបចំដោយខ្លួនឯងនូវដំណើរការនេះ ដែលកាន់តែបានល្អប្រសើរ ។

អំពីបញ្ហាផ្សព្វផ្សាយ ឯកឧត្តមយល់ថា មានការកែសំរួល និងការបើកទូលាយជាបន្តបន្ទាប់ ពីអាណត្តិមួយទៅអាណត្តិមួយ។ អស់លោកចោទថា គណបក្សកាន់អំណាចមានការផ្សព្វផ្សាយសំបូរបែប តាមពិតរដ្ឋគឺថាត្រូវតែដំណើរការផ្សព្វផ្សាយសកម្មភាពរបស់រដ្ឋាភិបាលក្នុងដំណាក់កាលបោះឆ្នោត គឺថាមានការឃោសនាឱ្យមានស្មើភាព អញ្ចឹងបញ្ហានេះ គឺថា គជប ឬក៏រដ្ឋសភាអាណត្តិ ក្រោយ ឬក៏យើងទាំងអស់គ្នាថាត្រូវធ្វើសំណើ ឬអនុសាសន៍យ៉ាងម៉េចដើម្បីកុំឱ្យមានបញ្ហាផ្សព្វផ្សាយនេះកើតឡើង ។ ឥឡូវនេះ ប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសយើងអាចគ្រប់គ្រងបាន។ ប៉ុន្តែប្រព័ន្ធផ្សព្វផ្សាយក្រៅប្រទេស យើងមិនអាចគ្រប់គ្រងបានទេ ជាក់ស្តែង គឺថាអស់លោក ឃើញហើយ រាល់ថ្ងៃនិយាយតែពីបញ្ហានយោបាយទេ មិនសូវមានបញ្ហាសង្គម ព្រោះថាប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសឯកជនគេមិនសូវគិតរឿងនយោបាយប៉ុន្មានទេ គេគិតតែពីរឿងផ្សព្វផ្សាយពាណិជ្ជកម្ម គេផ្សព្វផ្សាយរឿងមហោស្រព សិល្បៈដើម្បីទាក់ទាញឱ្យមានការគាំទ្រពីមហាជន។ យើងគួរតែពិចារណាបញ្ហានេះឱ្យបានគ្រប់ជ្រុងជ្រោយ យើងកុំសំដៅតែមួយជ្រុង កាលណាសំដៅតែមួយទិស គឺថាបញ្ហាមិនចេះចប់ទេ ព្រោះវាដោះស្រាយអត់ចំបញ្ហា។

អំពីបញ្ហាប្រកាសលទ្ធផលមុន គជប ឯកឧត្តមបានជំរាបថា កាលពីជំនាន់អ៊ុនតាក់បោះឆ្នោត គឺថាប្រកាសភ្លាម និងបន្តបន្ទាប់ពេលនោះគឺថាបញ្ហាបានចោទយ៉ាងខ្លាំង ព្រោះគាត់ប្រកាសនៅកន្លែងណាដែលគណបក្សប្រជាជនចាញ់ខ្លាំងមុនគេ នេះវាធ្វើឱ្យមានបញ្ហាជ្រួលច្របល់។ ព្រោះឯកឧត្តមជាអ្នកតាមដាន និង រៀបចំការងារនេះដោយផ្ទាល់ ឥឡូវនេះគឺថាមានបញ្ហាហ្នឹងកើតឡើងទៀត ប៉ុន្តែគ្រាន់តែជំរាបថា ឥឡូវប្រព័ន្ធបោះឆ្នោតស្រុកគេទំនើបណាស់ គ្រាន់តែបោះហើយមួយភ្លែត គេដឹងបាត់ហើយដោយសារតែប្រព័ន្ធព័ត៌មានវាររហ័ស លទ្ធផលតាមឃុំស្រុកមក គឺថានៅថ្នាក់កណ្តាលគេដឹងបាត់ហើយ ថានៅស្រុកនេះប៉ុន្មាន នៅខេត្តនេះប៉ុន្មាន គេអាចប៉ាន់ស្មានបានចំនួនកៅអីបានខ្លះៗ។ ប៉ុន្តែឯកឧត្តមជំរាបថា មិនមែនគណបក្សរបស់ឯកឧត្តមទៅប្រកាសលទ្ធផលជាផ្លូវការមុន គជប ទេ គឺដោយសារតែមានការលេចធ្លាយនូវព័ត៌មានខ្លះៗមកក្រៅតែប៉ុណ្ណោះ ហើយបញ្ហានេះបើ គជប មានគោលការណ៍យ៉ាងម៉េចសូមប្រាប់ឱ្យច្បាស់ថា មិនត្រូវផ្សព្វផ្សាយទេ។ ក៏ប៉ុន្តែរឿងហាមឃាត់មិនឱ្យគេដឹងលទ្ធផលមុន គឺថាយើងមិនអាចហាមឃាត់បានទេ ព្រោះនេះជាប្រព័ន្ធការងាររបស់គណបក្សនយោបាយមួយៗ ។

ចំពោះការអប់រំការងារការបោះឆ្នោត ឯកឧត្តមយល់ថាមិនមែនរឿង គជប មួយទេ ការអប់រំការងារបោះឆ្នោតគឺជាការងាររបស់គណបក្សនយោបាយ ជាការងាររបស់សង្គមស៊ីវិលទាំងអស់ ប៉ុន្តែគណបក្សនយោបាយត្រូវអប់រំសមាជិករបស់ខ្លួនឱ្យយល់អំពីការចុះឈ្មោះយ៉ាងម៉េចនិងត្រូវធ្វើយ៉ាងម៉េច។ ហើយពេលខ្លះនៅពេលដែលគណបក្សរបស់ឯកឧត្តមគ្រាន់តែមានករណីខ្លះនាំគ្នាទៅដាស់តឿនរំលឹកអំពីចុះឈ្មោះបោះឆ្នោត មាន NGOs ខ្លះបានចោទប្រកាន់ថាអញ្ចេះអញ្ចុះ ទៅជាអ្នកដែលសកម្មអប់រំប្រជាជនឱ្យទៅបោះឆ្នោតទៅជាអ្នកមានកំហុស ព្រោះខ្លះគេចាំតែចាប់កំហុសទេ។ ឯកឧត្តមបានលើកឡើងថាទំនាស់ដែលកើតឡើងភាគច្រើន គឺដោយសារពាក្យសំដី ឬវោហាសាស្ត្រនេះឯងដែលវាដុតកំដៅជាបន្តបន្ទាប់ កាលណាយើងមិនគោរពបទបញ្ជា ដូចរឿងឃោសនា

អញ្ជឹង ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាអត់មានចេញឃោសនាទេនៅពេលយុទ្ធនាការឃោសនា ដោយសារយើងមិនចង់ឱ្យវាកើតចេញនូវបញ្ហាហិង្សា ឬបញ្ហាអ្វីផ្សេងៗដែលកើតឡើង ។

អំពីបញ្ហាបណ្តឹង នេះជាសមត្ថកិច្ចរបស់ គជប ទេ ប៉ុន្តែឯកឧត្តមគ្រាន់តែជំរាបថា ការកាត់ក្តីតែពេលណាអ្នកចាញ់ គេតែងតែមានការថ្នាំងថ្នាក់ ដូចជាករណីនៅកំពង់ចាម នៅថ្នាក់ក្រោមគេកាត់ឱ្យគណបក្សប្រជាជនកម្ពុជាឈ្នះ ប៉ុន្តែឡើងមក គជប គណបក្សប្រជាជនកម្ពុជាចាញ់ ហើយរឿងនេះឯកឧត្តមមានទឡ្ហីករណ៍ច្បាស់ណាស់ថាមិនគួរត្រូវចាញ់ទេ។ ប៉ុន្តែធ្វើម៉េចបើ គជប គាត់ថាអញ្ចឹងហើយ ព្រោះមានសមាសភាពខាង គជប ជាអ្នកអនុមតិ ។ ដូច្នេះមិនមែនរាល់ក្តីសុទ្ធតែគណបក្សប្រជាជនកម្ពុជាឈ្នះទេ តែឥឡូវនេះគណបក្សប្រជាជនកម្ពុជា ក៏ចាប់ផ្តើមគិតអំពីបណ្តឹងត្រូវតែបង្រៀនមន្ត្រីរបស់ខ្លួនឱ្យបានយល់ច្បាប់អំពីបញ្ហានេះ។ ព្រោះកន្លងមកអត់សូវយកចិត្តទុកដាក់រឿងប្តឹងគេ គិតតែគេប្តឹងមកវិញ ហើយឯងនាំគ្នាគោរពច្បាប់ ដល់ពេលគេចាប់ផ្តើមតាមចាប់កំហុសរហូត។ ឯកឧត្តមបានបញ្ជាក់ថាអ្វីៗដែលបានលើកឡើងគឺគ្រាន់តែជាទឡ្ហីករណ៍ខ្លះឱ្យឃើញថា ដំណើរការវាមិនអាចនឹងសុក្រឹតទាំងស្រុង ទេ។ អញ្ចឹងហើយបានជាយើងចេះតែណែនាំគ្នារិះរកវិធីណាដើម្បីធ្វើឱ្យដំណើរការប្រជាធិបតេយ្យ ជាពិសេសដំណើរការបោះឆ្នោតដែលជាមូលដ្ឋានគ្រឹះនៃការបោះឆ្នោតកាន់តែប្រសើរឡើងជាលំដាប់ ។

លោកស្រី **លឹម ធីតា** តំណាងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាបានលើកយកបញ្ហាកម្មករកាត់ដេរទាក់ទងនឹងការបោះឆ្នោតមកជំរាបជូនអង្គប្រជុំ។ លោកស្រីបានសង្កេតឃើញថា មានបញ្ហាទាក់ទងទៅនឹងការកាត់ប្រាក់ឈ្នួលរបស់កម្មករ និងការឈប់សំរាកពេលជិតបោះឆ្នោតម្តងៗ។ ទាក់ទងទៅនឹងចំណេះដឹង និងការទទួលព័ត៌មាន លោកស្រីបានបញ្ជាក់ថា កម្មករកាត់ដេរប្រហែល ៩0% ជាកម្មការិនីដែលមកពីជនបទ មានចំណេះដឹងទាប ហើយអ្នកខ្លះអត់ចេះអក្សរ ហើយគ្មានពេលវេលាក្នុងការតាមដានព័ត៌មានស្តីពីការផ្សព្វផ្សាយនីតិវិធីក្នុងការបោះឆ្នោតទេ។ ដូច្នេះហើយធ្វើឱ្យពួកគាត់មិនសូវយកចិត្តទុកដាក់អំពីការបោះឆ្នោតទេ ផ្ទុយទៅវិញពួកគាត់ផ្តោតទៅលើជីវភាពរស់នៅជាសំខាន់។

ក្នុងនាមលោកស្រីជាតំណាងកម្មករវិស័យកាត់ដេរ លោកស្រីសូមអំពាវនាវដល់អង្គការនានា និងស្ថាប័នពាក់ព័ន្ធ ជួយផ្តល់ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំសហជីព សហព័ន្ធ បានយល់អំពីអត្ថប្រយោជន៍នៃការចូលរួមក្នុងការបោះឆ្នោត។ លោកស្រីតែងសង្កេតឃើញផងដែរថា នៅពេលជិតដល់ពេលបោះឆ្នោតមានគណបក្សជាច្រើនបានចុះទៅផ្តល់ជាពិធីជប់លៀង និងផ្តល់អំណោយផ្សេងៗ ដល់កម្មករ។ ត្រង់ចំណុចនេះ លោកស្រីយល់ថាគេគួរយកចិត្តទុកដាក់ក្នុងការផ្តល់វគ្គបណ្តុះបណ្តាល ឬក៏ធ្វើការផ្សព្វផ្សាយឱ្យថ្នាក់ដឹកនាំកម្មករបានយល់ដឹងអំពីអត្ថប្រយោជន៍នៃការបោះឆ្នោតវិញ វាជាការប្រសើរជាង ហើយពួកគេអាចធ្វើការបណ្តុះបណ្តាល ឬផ្សព្វផ្សាយបន្តដល់សមាជិករបស់ពួកគេ ឬក៏អាចផ្សព្វផ្សាយបន្តដល់ក្រុមគ្រួសាររបស់គេនៅតាមភូមិស្រុកផងដែរ ។

កញ្ញា **ចាវ ជាលីម** អនុប្រធានសមាគមនិស្សិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង បានលើកជាសំណូមពរ២ចំណុចៈ

ទី១ សំណូមពរចំពោះ គជប មេត្តាធ្វើយ៉ាងណាឱ្យការបោះឆ្នោតមានតម្លាភាព ហើយគ្មានអំពើហិង្សាជាពិសេសរវាងគណបក្សនិងគណបក្ស។

ទី២ សំណូមពរចំពោះគណបក្សទាំងអស់មេត្តាប្រកួតប្រជែងគ្នាក្នុងការបោះឆ្នោតដោយតម្លាភាព ប្រកបដោយការយោគយល់និងសហការគ្នា ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចំរើនដូចប្រទេសដទៃទៀត ។

ឯកឧត្ដម **អ៊ុក ភូរិ** បានមានប្រសាសន៍ថា ចំពោះការលើកឡើងរបស់សមាជិកអង្គប្រជុំម្នាក់ដែលថាសុំឱ្យខាងគណបក្សតូចៗ មានចិត្តក្លាហាន ប្រឹងតស៊ូដើម្បីបានកៅអីខ្លះហ្នឹងគេក្នុងព្រឹទ្ធសភានោះ ឯកឧត្ដមឆ្លើយតបថា ការបោះឆ្នោតព្រឹទ្ធសភានេះមិនខុសអំពីការដាក់ទឹកនៅលើថាសហើយហៅកុកមកផឹកទឹកទេ។ គណបក្សធំៗនាំគ្នាធ្វើច្បាប់សំរាប់តែខ្លួនឯងប៉ុណ្ណោះ បើសិនគណបក្សធំៗក្លាហានគួរធ្វើច្បាប់ឱ្យសមស្របតាមស្តង់ដារអន្តរជាតិមក កុំទៅយកតែតំណាងរាស្ត្រ ហើយនិងសមាជិកក្រុមប្រឹក្សាឃុំរបស់ខ្លួនតាមសមាមាត្រមកឱ្យបោះឆ្នោត សួរថាតើពួកគេបោះឆ្នោតឱ្យគណបក្សផ្សេងទេ? បើខ្លួនក្លាហានម្តេចមិនអនុញ្ញាតឱ្យតំណាងវិជ្ជាជីវៈឯករាជ្យផ្សេងៗចូលរួមបោះឆ្នោតផងទៅ។ សរុបសេចក្ដីមក គណបក្សធំៗធ្វើច្បាប់ចងគណបក្សតូចៗឱ្យស្លាប់ វាមិនខុសពីកូនក្មេងដែលទើបតែកើត ដែលគ្នាកំពុងតែផឹកទឹកដោះគោដើម្បីរស់ នាំគ្នាឡើងប្រដាល់ ១២ទឹក រឿងអីគ្នាមិនស្លាប់នោះ។

ឯកឧត្ដម ឧត្ដមសេនីយ៍ទោ **ណុប ស៊ីណូ** បានជំរាបអង្គប្រជុំថា ចំនួនអត្តសញ្ញាណប័ណ្ណប្រគល់ជូនប្រជាពលរដ្ឋមកទល់នឹងថ្ងៃនេះបានជិត៦លានសន្លឹកហើយ ចំពោះតួលេខជាក់ស្តែងថ្ងៃនេះឯកឧត្ដមមិនអាចជំរាបជូនបានទេ ព្រោះរបាយការណ៍ពីខេត្ត-ក្រុងបានផ្តល់មកជាបន្តបន្ទាប់។ ចំពោះតួលេខនៃចំនួនប្រជាពលរដ្ឋដែលខុសគ្នារវាង គជប និងក្រសួងមហាផ្ទៃនោះ ឯកឧត្ដមបានបញ្ជាក់ថា មូលហេតុមកពីប្រជាពលរដ្ឋខ្លះគាត់ផ្លាស់ប្តូរទីលំនៅដោយមិនជូនដំណឹងទៅសមត្ថកិច្ច ហើយទៅសុំចុះឈ្មោះម្តងទៀតនៅកន្លែងថ្មី។ នៅត្រង់ចំណុចនេះហើយដែលធ្វើឱ្យតួលេខមានគម្លាតគ្នារហូតជាង១សែននាក់នោះ។ តែទោះជាយ៉ាងណាក៏ដោយ ក៏សមត្ថកិច្ចទុកពេល៦ខែមុននឹងលុបឈ្មោះគាត់ចេញពីបញ្ជីបើសិនជាមានការផ្លាស់ប្តូរទីលំនៅ រីឯអ្នកចំណូលថ្មីក៏ទុកពេល៦ខែដែរមុនឱ្យចុះឈ្មោះក្នុងបញ្ជីថ្មីរបស់សមត្ថកិច្ច។

ចំពោះការដោះស្រាយពាក្យបណ្តឹង ឯកឧត្ដម **សុកលៈ ទីប៉ោ** បានបញ្ជាក់ថា រាល់បណ្តឹងដែលប្តឹង គជប បានចាត់ឱ្យនាយកដ្ឋានសេវាកម្មច្បាប់ចុះស្រាវជ្រាវដើម្បីរកអង្គហេតុ និងឯកសារពាក់ព័ន្ធផ្សេងៗដើម្បីដាក់ជូន គជប ពិនិត្យ និងសំរេច។ ដូច្នេះរាល់បណ្តឹងទាំងអស់ បើសិនជានាយកដ្ឋានសេវាកម្មច្បាប់គាត់ចុះទៅដល់មូលដ្ឋានដើម្បីស្រាវជ្រាវ ហើយរកឃើញថាបណ្តឹងណាមួយពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ គជប នឹងសំរេចតាមនីតិវិធីរបស់ខ្លួន ហើយបើដើមបណ្តឹងមិនសុខចិត្ត គេអាចប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញទៀត។ ទាក់ទងនឹងបណ្តឹងថាមានការលួចបន្លំសន្លឹកឆ្នោតបើមានភស្តុតាងគ្រប់គ្រាន់ គជប អនុញ្ញាតឱ្យរាប់សន្លឹកឆ្នោតឡើងវិញ ដូចជានៅខេត្តកំពង់ធំ គជប ពិនិត្យឃើញថាបណ្តឹងមានលក្ខណៈគ្រប់គ្រាន់សមហេតុផល គជប បានឱ្យរាប់ឡើងវិញ ។

លោក **ឱក សេរី សោភក្តិ៍** បានធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំខប់សែលឡឹមលើកទី១ដូចខាងក្រោមៈ

ទី១ គជប និងក្រសួងមហាផ្ទៃ មានតួលេខខុសគ្នាអំពីចំនួនប្រជាពលរដ្ឋ។

ទី២ ទាក់ទងទៅនឹងបញ្ហាប្រព័ន្ធផ្សព្វផ្សាយគឺធ្វើយ៉ាងណាផ្តល់ព័ត៌មានឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល។

ទី៣ រឿងបញ្ហាលិខិតបទដ្ឋាន ដែលទាក់ទងទៅនឹងក្របខ័ណ្ឌច្បាប់នានា ដូចជាបញ្ហារឿងការបកស្រាយច្បាប់ និងតួនាទីរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងការដោះស្រាយបណ្តឹងបោះឆ្នោត ។

ទី៤ នីតិវិធីរបស់ គជប ក្នុងការដោះស្រាយពាក្យបណ្តឹងមិនបានឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែងទេ។

ទី៥ ទាក់ទងទៅនឹងបញ្ហាបរិយាកាសសន្តិសុខ ការបំភិតបំភ័យ និងការស្បថស្បែរ បញ្ហាទាំងអស់នេះនឹងត្រូវលើកយកមកពិភាក្សាផងដែលនៅពេលក្រោយ។

ទី៦ ការធ្វើយ៉ាងណាដើម្បីឱ្យមានការអប់រំណែនាំបំពាក់បំប៉ន ដល់ភ្នាក់ងារអ្នកសង្កេតការណ៍របស់អង្គការ ឬមួយតំណាងគណបក្សនយោបាយនានាឱ្យបានទូលំទូលាយដើម្បីឱ្យមានលក្ខណៈជាអាជីព។

ទី៧ បញ្ហាតម្លាភាព ដែលមានការចោទប្រកាន់ថាមានការលួចបន្លំសន្លឹកឆ្នោត ហើយមិនត្រូវបានអនុញ្ញាតឱ្យមានការរាប់សន្លឹកឆ្នោតឡើងវិញនៅមណ្ឌលខ្លះ។ អង្គប្រជុំនឹងពិភាក្សាគ្នាថាតើការចោទប្រកាន់ទាំងនោះឈរលើមូលដ្ឋានអ្វី តើមានភស្តុតាងដែរឬទេ?

ទី៨ បញ្ហាការប្រកាសលទ្ធផល ដែលមានការមិនទាន់ទុកចិត្តអំពីការគ្រប់គ្រងរបស់ គជប ទៅលើការប្រកាសលទ្ធផល ដោយសារមានការប្រកាសលទ្ធផលមុនពីសំណាក់គណបក្សនយោបាយ ហើយអង្គប្រជុំនឹងពិនិត្យមើលបញ្ហានេះឡើងវិញ។

ទី៩ ហេតុអ្វីបានជាចុះលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅលើទំរង់បែបបទលេខ ១១០៣ ហើយចម្លងបន្តទៅទំរង់បែបបទ លេខ ១១០៥វិញ ហើយមានប្រើទឹកលប់ទៀត។ តើហេតុអីបានជាចាំបាច់មានទំរង់បែបបទ ១១០៣ ហើយមានទំរង់បែបបទ ១១០៥ ទៀត?

ទី១០ ស្នើសុំឱ្យអង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធផ្តល់នូវវគ្គបណ្តុះបណ្តាល ដើម្បីឱ្យកម្មករមានការយល់ដឹងអំពីសារៈប្រយោជន៍ នៃការចូលរួមក្នុងការបោះឆ្នោត។ បញ្ហាច្បាប់ឈប់សំរាក បញ្ហាចុះឈ្មោះ បញ្ហាពេលវេលាដើម្បីទៅបោះឆ្នោត។

ទី១១ និស្សិតមិនសូវមានការយល់ដឹងអំពីការចូលរួមនៅក្នុងយន្តការបោះឆ្នោត ហើយអង្គប្រជុំសង្ឃឹមថាអង្គការឯទៀតៗ និងស្ថាប័នពាក់ព័ន្ធនឹងជួយក្នុងការបំពាក់បំប៉ននិស្សិតទាក់ទងទៅនឹងយន្តការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជាក្នុងពេល៣ឆ្នាំខាងមុខនេះ។

មុននឹងបញ្ចប់កិច្ចប្រជុំ លោក **ឱក សេរី សោភ័ក្តិ** បានថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងអស់ដែលចំណាយពេលវេលាអញ្ជើញចូលរួមក្នុងកិច្ចប្រជុំខប់សែលឡឹមលើកទី១ នេះ និងមានមតិយ៉ាងផុសផុល។

**កាលបរិច្ឆេទនៃកិច្ចប្រជុំខប់សែលឡឹមលើកទី២ នឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥ នៅ វ.ប.ស.អ ។**